00344451

Decalssified to Public
06 September 2012

E1/36.1

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ

# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"

## អសាធារណៈ:

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩**

**សវនាការលើកទី៣២**

**កិច្ចប្រជុំរៀបចំសវនាការ**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម ស៊ុយហុង

លោក ឌុច ផារី

លោកស្រី សែ កុលវុឌ្ឍី

លោក ម៉ាត្ទូ គ្រីស្ពារ *(Mr. Matteo Crippa)*

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក យ៉េត ចរិយា

លោក វីលៀម ស្មីត *(Mr. William Smith)*

លោក ពេជ្រ សម្បត្តិ

លោក ហ្សាឆិរី ឡាំប៉ែល

*(Mr. Zachery Lampell)*

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**ជនជាប់ចោទ៖**

លោក កាំង ហ្គេក អ៊ាវ

**មេធាវីការពារជនជាប់ចោទ ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ

*(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក យុង ផានិត

លោក គឹម ម៉េងឃី

លោក ហុង គឹមសួន

កញ្ញា ម៉ុច សុវណ្ណារី

កញ្ញា ទី ស្រីនណា

លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី

*(Ms. Silke Studzinsky)*

លោក អាឡាំង វែនណឺ

*(Mr. Alain Werner)*

កញ្ញា ចេស្ស៊ីកា ហ្វីណែល

*(Ms. Jessica FINELLE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនះ

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក គឹម ម៉េងឃី | ខ្មែរ |
| លោក គង់ ពិសី | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ | បារាំង |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោក វីលៀម ស្មីត | អង់គ្លេស |
| លោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី | អង់គ្លេស |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |

អសាធារណៈ

# កិច្ចដំណើរការនីតិវិធី

[១៣:៣៣:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។

ថ្ងៃនេះ ក្នុងនាមខ្ញុំជាប្រធាន អង្គជំនុំជម្រះនិងជំនួសមុខឲ្យចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ខ្ញុំសូមសម្តែងនូវមនោសញ្ចេតនាស្វាគមន៍ចំពោះវត្តមានរបស់អស់លោក លោកស្រី នាងកញ្ញាចំពោះការអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំរៀបចំសវនាការនៅរសៀលនេះ ។ បន្ទាប់ពីបានផ្លាស់ប្តូរយោបល់ជាមួយនឹងភាគីនានាក្នុងអំឡុងពេលនៃកិច្ចប្រជុំសវនាការកាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ កន្លងមក ភាគីខ្លះបានស្នើសុំដល់អង្គជំនុំជម្រះឲ្យពិនិត្យលទ្ធភាពមួយចំនួន ដែលក្នុងនោះមានការស្នើសុំផងដែរនូវការកាត់បន្ថយនូវចំនួនសាក្សីដើម្បីឲ្យការជំនុំជម្រះអាចប្រព្រឹត្តទៅបានប្រកបដោយភាពឆាប់រហ័ស និងរក្សាបាននូវភាពយុត្តិធម៌ ។

ទន្ទឹមនឹងនេះដែរ លទ្ធផលដែលបានឆ្លើយតបលើការស្នើសុំរបស់មេធាវីការពារក្តី លោក ហ្វ្រង់ស្វ័រ រ៉ូ ដែលបានស្នើសុំពីព្រឹកមិញនេះ ។ ឥឡូវនេះ អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការពិភាក្សាផ្តោតជាសំខាន់ទៅលើបញ្ហាទាក់ទិនជាមួយនឹងសាក្សី ។ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការបែងចែកនូវកំណត់សម្គាល់របស់ខ្លួនអំពីសាក្សីនេះរួចហើយជូនដល់ភាគីកាលពីថ្ងៃច័ន្ទទី២២ ខែមិថុនា ឆ្នាំ២០០៩ កាលពីម្សិលមិញនេះ។ អង្គជំនុំជម្រះសូមសួរថា តើមានភាគីណាមានចំណាប់អារម្មណ៍ទៅលើបញ្ហានេះដែរ ឬទេ? ជាពិសេសកំណត់សម្គាល់របស់អង្គជំនុំជម្រះដែលបានធ្វើការបែងចែករួចហើយ ។

ហើយសូមបញ្ជាក់ឲ្យកាន់តែច្បាស់ជាងនេះទៅទៀតនោះ គឺថារបៀបវារៈដែលយើងជជែកវែកញែកគ្នានៅថ្ងៃនេះ ពិភាក្សា និងរកដំណោះស្រាយនោះគឺមានចំនួនបួន ។ ទីមួយ បញ្ហាឈ្មោះសាក្សីដែលស្នើឲ្យដកចេញពីបញ្ជីឈ្មោះសាក្សី ។ ទីពីរ គឺបញ្ជីឈ្មោះសាក្សីដែលអង្គជំនុំជម្រះស្នើសុំឲ្យមានការបំភ្លឺពីភាគីដែលបានស្នើសុំឲ្យអង្គជំនុំជម្រះស្តាប់សាក្សី ។ ទីបី សាក្សីដែលអង្គជំនុំជម្រះសាលាដំបូងនឹងបន្ថយរយៈពេលសម្រាប់ធ្វើសក្ខីកម្ម ។ ទីបួន បញ្ជីឈ្មោះសាក្សីដែលត្រូវបានស្នើសុំធ្វើសក្ខីកម្មពីចម្ងាយតាមរយៈវីដេអូ *ខនហ្វឺរិន* ។ នេះជារបៀបវារៈដែលយើងជជែកពិភាក្សាគ្នាថ្ងៃនេះ ក្នុងគោលបំណងគឺដើម្បីបុព្វហេតុយុត្តិធម៌និងឆាប់រហ័ស ។

ហើយនៅក្នុងកិច្ចពិភាក្សានេះផងដែរ អង្គជំនុំជម្រះសូមជម្រាបភាគីថាសូមរក្សានូវការប្រើ

រហស្សនាមសាក្សីដែលមិនទាន់បានធ្វើសក្ខីកម្មលើកលែងតែអ្នកជំនាញ ឬក៏សាក្សីដែលជាជនបរទេស ដែលតាំងពីដំបូងមកយើងមិនបានកំណត់ឈ្មោះរហស្សនាមជូនទេ ។ តើភាគីមានបញ្ហាអ្វីដែលទេ លើអ្វីដែលជារបៀបវារៈបានលើកឡើងនេះ?

សហព្រះរាជអាជ្ញាតើមានបញ្ហាអីទេ? តំណាងសហ-- អញ្ជើញលោក លោកស្រីចៅក្រម ។

[១៣:៣៧:៤៦]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណច្រើនលោកប្រធាន ។ យើងបានយល់ថា ការិយាល័យសហព្រះរាជអាជ្ញាបានស្នើរយៈពេលកន្លះម៉ោងទៀតមុនពេលដែលកិច្ចប្រជុំនេះចាប់ផ្ដើម ។

**លោក វីលៀម ស្មីត៖**

ខ្ញុំស្នើសុំទៅដល់ភាគី តើភាគីចង់បានរយៈពេលបន្ថែមទៀតដែរឬទេ? យើងប្រហែលជាចង់ហើយយើងនឹងផ្ដល់ព័ត៌មានជាច្រើននៅពេលនេះ ។ ក៏ប៉ុន្តែ ព័ត៌មានទាំងអស់នោះ គឺមិនជាព័ត៌មានទាំងស្រុងនោះទេ។ ដូច្នេះហើយ លោក លោកស្រី នឹងទទួលបានព័ត៌មានកៅសិបនាទី ឬក៏យើងនឹងធ្វើឡើងក្នុងរយៈពេលម្ភៃនាទី ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំគិតថា អង្គសវនាការនឹងផ្ដល់រយៈពេលបន្ថែមទៀតនៅពេលនេះដើម្បីអនុញ្ញាតឲ្យភាគីទាំងអស់មានការរៀបចំឲ្យបានត្រឹមត្រូវ ។ ហើយលោកប្រធានបានបញ្ជាក់រួចហើយថា យើងសូមថ្លែងអំណរគុណចំពោះភាគីដែលបានយល់ស្របទៅលើករណីនៃការរៀបចំកិច្ចប្រជុំនេះក្នុងពេលលឿននេះ ។ ហើយខ្ញុំដឹងថា យើងវាហាក់ដូចជាដាក់សម្ពាធទៅដល់ភាគីទាំងអស់ ប៉ុន្តែយ៉ាងណាក៏ដោយ គឺយើងទាំងអស់គ្នាបានដឹងថាករណីដែលយើងប្រជុំនេះគឺវាជាករណីពិសេសមួយ ។

ហើយអង្គសវនាការ ហើយខ្ញុំដឹងដែរ គឺភាគីគាត់ចង់ធ្វើឡើងដើម្បីសម្រួលទៅដល់លោក រូ ។ ហើយខ្ញុំបានកត់សម្គាល់មុននេះហើយ កញ្ញា ស្ទួតហ្សីនស្គី ថាលោកស្រីបានលើកឡើងថា តើលោកស្រីត្រៀមខ្លួនរួចទេចូលរួមនៅក្នុងពេលនេះ? ហើយខ្ញុំសុំសួរទៅកញ្ញាថា តើកញ្ញាទទួលយកទៅលើការរៀបចំកិច្ចប្រជុំនេះក្នុងលក្ខណៈពិសេសនេះដែរឬទេ ដោយសារតែលោកស្រីជាមេធាវីមានបទពិសោធន៍ ហើយៗយើងដឹងអំពីការរៀបចំនេះថា តើកញ្ញាអាចចូលរួមដែរឬទេ?

**លោកស្រី ស៊ីលឃី ស្ទូតហ្សិនស្គី៖**

ខ្ញុំអាចឆ្លើយតបទៅនឹងសំណួរបីក្នុងចំណោមទាំងបួន ។ ហើយខ្ញុំនឹងស្នើសុំធ្វើការព្យួរទុកចំពោះឧបសម្ព័ន្ធ “ខ” ទាក់ទងទៅនឹងសាក្សី CP ពីរ ។ ហើយចំពោះសាក្សីផ្សេងទៀតយើងអាចឆ្លើយតបបាន ។ សូមអរគុណ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

វាហាក់ដូចជាមានការអន់ចិត្តដោយសារតែយើងមិនអាចធ្វើការព្យួរ ឬក៏ពន្យារនៅពេលនេះទេ។ យើងត្រូវតែធ្វើសេចក្តីសម្រេចឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ។ ហើយខ្ញុំដឹងថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតគឺគាត់យល់ស្របទៅលើករណីនេះ ។ នៅក្នុងកិច្ចប្រជុំនេះគឺវាអាស្រ័យទៅលើការរៀបចំសវនាការរបស់យើងរយៈពេលអាទិត្យបន្ទាប់ ដូច្នេះហើយគឺក្នុងអាទិត្យនេះ គឺយើងត្រូវការការសហការគ្នា ។ ហើយដោយផ្អែកទៅលើបទពិសោធន៍របស់លោក លោកស្រីហ្នឹង គឺ លោកស្រីនឹងអាចធ្វើបាន ។ ដូច្នេះហើយ កញ្ញា ឬក៏មេធាវីអាចធ្វើការដោះស្រាយចំពោះបញ្ហាដែលថា មានការសុំព្យួរនេះ ។ លោកប្រធានថា តើលោកប្រធានចង់ឲ្យខ្ញុំផ្តល់យោបល់លើចំណុចផ្សេងទៀតដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញៗលោកស្រី ដើម្បីពន្យល់ភាគីពាក់ព័ន្ធឲ្យច្បាស់ដើម្បីឲ្យយើងចូលត្រឡប់មកវិញគឺមានការជជែកពិភាក្សាបានលឿនតែម្តង។ សូមអញ្ជើញ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

ហើយលោកប្រធានគឺថា យើងអាចចាប់ផ្តើមនៅក្នុងរយៈពេលសាមសិបនាទីទៀតនេះ គឺនៅម៉ោងពីរដប់នាទី ។

*[កិច្ចប្រជុំសម្រាកពីម៉ោង ១៣:៤២ នាទី ដល់ម៉ោង ២:១០ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។ យើងបន្តកិច្ចប្រជុំរបស់យើងតាមរបៀបវារៈ ដែលយើងខ្ញុំបានជម្រាបជូន ភាគីនិងអ្នកចូលរួមរួចហើយ ។ ឥឡូវនេះ យើងពិភាក្សានូវរបៀបវារៈទីមួយ មួយម្តងៗ ។ ទីមួយគឺរបៀបវារៈទីមួយស្តីពីបញ្ជីឈ្មោះសាក្សីដែលស្នើឲ្យដកចេញពីបញ្ជីឈ្មោះសាក្សី ។

នៅក្នុងនេះគឺអស់លោក លោកស្រីភាគីទាំងអស់មានហើយ គឺខ្ញុំអានឡើងវិញ គឺមានចំនួនដូចខាងក្រោមនេះ៖

KW12, KW13, KW14, KW16, KW17, KW18, KW19, KW25, CP2/6 (A05), CP2/7 (A06), និក ដនឡុប, KW27, KW28, CP2/4 (A04), KW06, CP2/10, ប្រាអ៊ូលម៉ាកជេនណា ។

សូមដាក់ពិភាក្សា តើភាគីណាមានហេតុផលពិសេស អ្វីដើម្បីទុកសាក្សីទាំងនេះ ដើម្បីដាក់ក្នុងបញ្ជីឈ្មោះត្រូវធ្វើសក្ខីកម្មដែរឬទេ? ដោយហេតុថាអង្គជំនុំជម្រះ ទោះបីលើកសំណើនេះជូនដល់ភាគីក៏ដោយក៏អង្គជំនុំជម្រះយល់ថា សាក្សីទាំងអស់នេះ ដែលបានស្នើនេះ គឺបានស្តាប់ចម្លើយដោយសហចៅក្រមស៊ើបអង្កេតរួចហើយ ហើយអង្គជំនុំជម្រះនឹងលើកយកកំណត់ហេតុស្តាប់ចម្លើយយកមកអានតាមករណីសមស្រប ។

ដូចនេះ សូមពិនិត្យលើបញ្ជីឈ្មោះទីមួយមុន ។ ហើយអង្គជំនុំជម្រះសូមជម្រាបផងដែរថា ភាគីណាដែលយល់ឃើញថាមានសារៈសំខាន់មិនព្រមដកចេញតាមបញ្ជីបានស្នើឡើងនេះ ។ សូមភាគីនោះបង្ហាញនូវហេតុផលជាក់លាក់នៃមូលហេតុនៃការដែលមិនយល់ព្រមផង ដើម្បីឲ្យអង្គជំនុំជម្រះយកមកពិនិត្យពិចារណាសម្រេចនៅក្រោយពេលដែលប្រជុំនេះចប់ ។ សូមអញ្ជើញ បានជាតំណាងសហព្រះរាជអាជ្ញាមុន ។

**លោក វីលៀម ស្មីត៖**

សូមគោរព លោក លោកស្រីចៅក្រម! សូមអរគុណជាថ្មីដែលអនុញ្ញាតឲ្យផ្តល់ឱកាសឲ្យភាគីក្នុងការពិភាក្សា និងផ្តល់យោបល់ផ្សេងៗទាក់ទងទៅនឹងកិច្ចប្រជុំរៀបចំសវនាការ ។ សហព្រះរាជអាជ្ញាមានការស្វាគមន៍ចំពោះសេចក្តីសម្រេចនេះ ដើម្បីសម្រួលទៅលើរឿងក្តីរបស់យើង ហើយនិងឲ្យរឿងក្តីនេះ បញ្ចប់ឲ្យបានឆាប់ ហើយក៏ដូចតែថាយើងធានាទៅលើយុត្តិធម៌ រកយុត្តិធម៌ចំពោះអ្វីដែលកើតមាននៅស-២១ ។ ហើយឲ្យសាធារណជន គាត់បានយល់អំពីចំណុចទាំងអស់នេះ ។ ទាក់ទងទៅនឹងការដកឈ្មោះចេញពីបញ្ជីឧសម្ព័ន្ធមួយ បញ្ហាផ្លូវច្បាប់ និងការមិនកោះហៅចូលក្នុងសវនាការហើយនិងវាទាក់ទងទៅនឹងការយល់ឃើញរបស់សាធារណជន ដើម្បីឲ្យសាធារណជនពិនិត្យ និងស្តាប់សាក្សីហើយតុលាការដើរតួនាទីសំខាន់នៅក្នុងនេះ ហើយតុលាការគឺតម្រូវឲ្យបំពេញការងារក្នុងការធានាក្នុងការមានការជំនុំជម្រះមួយដោយយុត្តិធម៌និងលឿន ។ ដោយផ្អែកទៅលើចម្លើយផ្សេងៗរបស់សាក្សីទាំង

អស់នេះ ដែលយើងនឹងយកមកពិចារណាតាមនីតិវិធាន៨៧.៣ ។ សហព្រះរាជអាជ្ញាសូមធ្វើការសន្និដ្ឋានថាសេចក្តីសម្រេច ថាតើយើងកោះហៅ ឬមិនកោះហៅសាក្សីនោះ? គួរតែធ្វើការពន្យាររយៈពេលបួនទៅប្រាំអាទិត្យទៀត ។ នៅក្នុងការលើកឡើងដូច្នេះ គឺយើងមិនមែននិយាយថា លោកចៅក្រមមិនមែនថាមិនឲ្យបន្តទៅលើដំណើរការក្តីនោះទេ កាលដែលយើងចង់ដើរដាក់សាក្សីនេះគឺថាយើងដាក់ជាបញ្ជីព្យួរទុកព្រាងមួយ ។ ហើយយើងបញ្ចូលបញ្ជីសាក្សីនោះទៅតាមរឿងក្តី ចង់ឲ្យរឿងក្តីនោះវាបញ្ចប់ហើយចំណុចនេះ គឺយើងនឹងដកសាក្សីមួយចំនួននៅក្នុងនេះ ។ ហើយនៅក្នុងបញ្ជីព្យួរនេះគឺថាភាគីអាចព្យួរសិទ្ធិរបស់ខ្លួននៅក្នុងការលើកបញ្ហានេះ ក្នុងរយៈពេលបួននិងប្រាំអាទិត្យទៀត នៅពេលដែលលោកលោកស្រីចៅក្រម យល់ឃើញថា យើងស្តាប់ភស្តុតាងគ្រប់គ្រាន់ហើយ ។

[១៤:១៧:១៩]

ហើយហៅថា គោលបំណងមួយចំនួនបានទទួល ហើយសាធារណជនគឺគាត់បានស្តាប់ទៅលើភស្តុតាង ហើយដែលអង្គសវនាការគិតថាវាចាំបាច់ ។ សេចក្តីសម្រេចថា សាក្សីបន្ថែមនៅក្នុងបញ្ជីព្យួរទុកនេះ អាចកោះហៅ ឬមិនកោះនោះ គឺអាចសម្រេចនៅពេលដែលវាស្ថិតនៅក្នុងស្ថានភាពមួយទៀតដែលយើងអាចធ្វើការវិភាគទាក់ទងទៅនឹងបញ្ហាផ្លូវច្បាប់ ដូចដែលលោក លោកស្រី បានដឹងហើយជនជាប់ចោទ គាត់បានបញ្ជាក់ថាគាត់មិនថិតនៅក្នុងទីតាំងមួយចំនួនដែលឧក្រិដ្ឋកម្មកើតឡើង ។ ដូច្នេះហើយការបង្ហាញឲ្យហួសពីមតិសង្ស័យនៅក្នុងចំណុចមួយចំនួននោះ គឺវាមិនមែនកើតចេញពីជនជាប់ចោទខ្លួនឯងនោះទេ គឺវាត្រូវផ្តល់ពន្លឺតាមរយៈសាក្សី ។ នៅពេលដែលខ្ញុំលើកឡើងចំណុចនេះ នេះជាជំហរទីមួយនិងសំណើទីមួយរបស់ខាងសហព្រះរាជអាជ្ញាថា បញ្ជីសាក្សីនេះគឺទុកជាបញ្ជីបម្រុង ហើយបញ្ជីដែលនៅសល់គឺយើងអាចប្រមូលផ្តុំគ្នា ដែលលោកចៅក្រមគិតថាសមរម្យ ។ យើងមិនមែនថាចង់ឲ្យព្យួរសេចក្តីសម្រេចរបស់លោក លោកស្រីចៅក្រមនោះទេ ។ ហើយយើងចង់ឲ្យ មិនមែនថាយើងចង់ឲ្យមកទាំងអស់គ្នាទេ ចំពោះសាក្សីទាំងអស់នោះ ។ នៅក្នុងបទពិសោធន៍របស់យើង នៅក្នុងរឿងក្តីផ្សេងៗ អ្វីដែលវាអាចកើតឡើងនោះ គឺនៅក្នុងរឿងក្តីដែលវាឧក្រិដ្ឋកម្មកើតឡើងសាមសិបឆ្នាំហើយនោះ គឺការចងចាំរបស់ប្រជាជន របស់ជនទាំងឡាយគឺវាថយ ជាពិសេសសាក្សីដែលវាថិតនៅក្នុងចំណោមសាក្សីដែលលោក លោកស្រីចៅក្រម ចង់ដកនេះ ។ អ្នកទាំងអស់នោះ គឺថាគាត់មិនពាក់ព័ន្ធឬក៏មិនដឹងអំពីការពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឡើងនៅក្នុងស-២១ ។ ដូច្នេះហើយវាអាចថាគ្រប់សាក្សីក្រុមទីមួយ ដែលមកក្នុងសវនាការនោះ គ្រាន់តែចង់ផ្តល់សិទ្ធិនៅក្នុងការមិនដាក់បន្ទុកខ្លួនឯង តាមវិធាន

ទី២៨ ។ ហើយខ្ញុំជឿថា អង្គសវនាការមានលទ្ធភាពក្នុងការសម្រេច ថាតើសាក្សីនោះគួរតែបង្ខំឲ្យមកផ្តល់សក្ខីកម្មដែរឬទេ? ហើយយើងត្រូវចាំអំពីភាពទម្ងន់នៃភស្តុតាងផ្សេងៗ ។ នេះគឺជាជំហរទីមួយរបស់យើងខ្ញុំ ហើយកាលដែលយើងលើកឡើងគឺវាអនុញ្ញាតឲ្យអង្គសវនាការគឺអាចគ្រប់គ្រងតាមដែលលោក លោកស្រីចៅក្រម ធ្វើទៅបាន យើងខ្ញុំសូមស្វាគមន៍ ។ ហើយភាគីគឺចង់មានលទ្ធភាពក្នុងការកោះហៅសាក្សី ។ លោក លោកស្រីចៅក្រម អាចមានលទ្ធភាពក្នុងការកោះហៅសាក្សីមួយ ឬក៏ពីរក្នុងចំណោមនេះ ប្រសិនបើគិតថាភស្តុតាងវាពាក់ព័ន្ធ ។ ប៉ុន្តែ វាយ៉ាងណាក៏ដោយ វាមិនអាចកើតឡើងជាញឹកញយនោះទេ ។

[១៤:២០:២៩]

ហើយនៅពេលនេះ វាមានភាពចាំបាច់ក្នុងការទស្សន៍ទាយទៅលើចំណុចនេះ ។ នៅពេលដែលខ្ញុំលើកឡើងចំណុចនេះ គឺយើងត្រូវគិតអំពីថាតើយើង ភស្តុតាងវាចេញពីជនជាប់ចោទយ៉ាងម៉េច? នៅក្នុងអំឡុងពេលពីរបីអាទិត្យកន្លងទៅនេះ ដែលពេលខ្លះទៅវាមានភាពពេញលេញ ។ ហើយយើងសង្ឃឹមថាបន្ទាប់ពីសាក្សីដប់និងដប់ប្រាំ ដែលយើងកោះហៅមកនោះ ប្រហែលជាវាអាចកិច្ចលើកឡើងដូចគ្នានៅក្នុងការយល់ឃើញរបស់សាក្សី ។ ហើយភាគីអាចគិតថា វាមានលក្ខណៈគ្រប់គ្រាន់ហើយចំពោះភស្តុតាងទាំងឡាយ ដើម្បីឲ្យសាធារណជនគាត់បានស្តាប់និងដឹង ។ ដូច្នេះ គឺជាការលើកឡើងរបស់ខ្ញុំ ហើយមិនមានការប៉ះពាល់ទៅនឹងគម្រោងផែនការរបស់លោក លោកស្រីចៅក្រម នោះទេ ។ ការលើកឡើងរបស់ខ្ញុំទីពីរ ប្រសិនបើលោក លោកស្រីចៅក្រម ធ្វើសេចក្តីសម្រេចនៅថ្ងៃនេះ គឺខ្ញុំ-- ដូចលោក លោកស្រីចៅក្រម បានលើកឡើងហើយ យើងនឹងពិចារណាចម្លើយសាក្សីតាមវិធាន៨៧ ទោះបីជាយើងអាន ឬក៏មិនអានជូនសាធារណជនក៏ដោយ វាជាបញ្ហាផ្លូវច្បាប់ យើងត្រូវដឹងទៅលើបញ្ហានេះដែលថាយើងនឹងយកមកពិចារណានៅក្នុងសាលក្រមរបស់យើង ។ ហើយប្រសិនបើចម្លើយ-- ហើយប្រសិនបើជាមេធាវីការពារក្តី គាត់ជំទាស់ទៅលើចម្លើយរបស់ *អូស៊ីអាយជេ* នោះ ឬក៏គាត់ចង់ធ្វើការតតាំងនោះ គឺយើងនឹងកោះហៅសាក្សី ។ ខ្ញុំមិនគិតថា យើងនឹងអានចម្លើយសាក្សីទេ ហើយមេធាវីគាត់ធ្វើការឲ្យតវ៉ាទៅលើខ្លឹមសារសំខាន់នោះទេ ។ ហើយវាទាក់ទងទៅនឹងការចោទប្រកាន់និងការចូលរួមរបស់ជនជាប់ចោទនៅក្នុងឧក្រិដ្ឋកម្ម ។ ចំណុចទាំងអស់នេះ គឺជាការលើកឡើងបឋមរបស់ខ្ញុំ ហើយចំពោះសាក្សីដើមបណ្តឹងរដ្ឋប្បវេណី គឺយើងមិនមានយោបល់ទៅលើចំណុចនេះទេ ។ លោក លោកស្រីចៅក្រម អាចធ្វើការសម្រេច សំណួរមួយនោះគឺថា KW25 គឺមាននៅក្នុងឧបសម្ព័ន្ធ “ក” ហើយក៏យើង

ឃើញមាននៅក្នុងឧបសម្ព័ន្ធ “គ” ផងដែរ ។ ហើយតើលោក លោកស្រីចៅក្រម អាចធ្វើការបំភ្លឺយើងខ្ញុំគឺថាសាក្សីនេះ អាចធ្វើការដកចេញដែរឬទេ? ឬក៏យើងយកមកពិចារណាតាមវិធាន៨៧ ។ យើងមានការលើកឡើងទីបី ប៉ុន្តែប្រសិនបើ លោក លោកស្រីចៅក្រម យល់ព្រមតាមចំណុចទីមួយនិងទីពីរ យើងនឹងមិនលើកទៅលើចំណុចទីបីនោះទេ ។ ហើយចំពោះសាក្សីមួយចំនួននោះ គឺខ្ញុំគិតថា តើលោក លោកស្រីចៅក្រម យល់ព្រម ឬមិនព្រម ទៅលើការបង្កើតបញ្ជីបម្រុង? ហើយយើងអាចមានបញ្ជីនេះ ឬក៏យើងរង់ចាំទៅលើករណីនេះ?

[១៤:២៣:៥០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ប្រហែលជាមានបញ្ហានៃការបកប្រែ វាជាបញ្ហាសំខាន់ដើម្បីឲ្យយើងបានយល់ឲ្យច្បាស់នៅលើចំណុចមួយចំនួនដែលអង្គសវនាការមានបំណងក្នុងចង់ឲ្យមានការបំភ្លឺ ។ យើងបានបង្កើតបញ្ជីសាក្សីអំពី-- វាហាក់ចំពោះបុគ្គលណានោះ វាហាក់ដូចជាមិនចាំបាច់ចំពោះយើង ថាយើងត្រូវស្តាប់បុគ្គលណានោះទេ ។ យើងចង់បញ្ជាក់ថានៅវសៀលនេះ គឺយើងចង់បានយល់របស់ភាគីទាក់ទងទៅនឹងមូលហេតុផ្សេងៗ ឬក៏មូលហេតុដែលលើកលែងណាមួយដែលថា ការមកចូលរបស់សាក្សីទាំងអស់នោះ គឺវានឹងភាពចាំបាច់ចំពោះភាគី ដូចដែលបានលើកឡើងរួចហើយ ។ យើងពិចារណាថា ពិចារណា លទ្ធភាពក្នុងការប្រើប្រាស់ចម្លើយដែលបានបង្កើតនៅក្នុងតំណាក់កាលស៊ើបអង្កេត ដោយចៅក្រម ។ ហើយចម្លើយទាំងអស់នោះត្រូវបានកត់ទុកយ៉ាងត្រឹមត្រូវដោយអ្នកស៊ើបអង្កេត ឬក៏ដោយសហចៅក្រមស៊ើបអង្កេត ឬក៏ប្រហែលត្រូវបានកត់ត្រាត្រឹមត្រូវដោយការិយាល័យសហព្រះរាជអាជ្ញា ហើយវាក៏ត្រូវដកបញ្ចូល-- ដកចេញទៅលើចម្លើយផ្សេងៗ ដែលរៀបចំឡើងដោយ *អិនជីអូ* ឬក៏អង្គភាពផ្សេងៗ ឬក៏សារព័ត៌មាន ។ល។ ដូច្នេះខ្ញុំសូមនិយាយឡើងវិញ អ្វីដែលយើងចង់បាននិងចង់ដឹងនៅពេលនេះគឺថា តើភាគីមានមូលហេតុអ្វីខ្លះ? ឬមានបំណងអ្វីខ្លះ? ដែលថាចង់ឲ្យសាក្សីនេះចូលខ្លួន ។ ហើយលើកឡើងថា ការចូលខ្លួនរបស់សាក្សីនេះមានសារសំខាន់ ហើយប្រសិនបើចំណុចនេះទទួលស្គាល់ដោយមេធាវីការពារក្តីនោះ គឺវាហាក់ដូចជាមិនចាំបាច់មានការតទល់នៅក្នុងសវនាការរបស់យើង។ ដូច្នេះ ហើយធ្វើយ៉ាងណាឲ្យយើងខ្ញុំបានយល់ឲ្យបានច្បាស់លាស់ទៅលើករណីនេះ ។

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកចៅក្រម ។ ទាក់ទងទៅនឹងបញ្ហានេះគឺខាងមេធាវីការពារ ហើយនិងសហព្រះរាជអាជ្ញាហៀបនឹងមានកិច្ចព្រមព្រៀងហើយថា ចម្លើយរបស់ជនជាប់ចោទដែលបានធ្វើឡើងគប្បីដាក់មកដេញដោលនៅអង្គជំនុំជម្រះតាមវិធាន៨៧.៣ ។ ហើយដល់អ៊ីចឹង ហើយយើងបម្រុងនឹងមានកិច្ចព្រមព្រៀងហើយថា ចម្លើយទាំងអស់របស់សាក្សីនៅក្នុងសហចៅក្រមស៊ើបអង្កេតនឹងដាក់ចូលទៅក្នុងសំណុំរឿងតាមវិធាន៨៧.៣ ។ ហើយសហព្រះរាជអាជ្ញាមិនចង់ឲ្យភស្តុតាងទាំងឡាយដែលប្រមូលបានដោយសហចៅក្រមស៊ើបអង្កេតហ្នឹង ក្លាយទៅជាមិនបានប្រយោជន៍នោះទេ ហើយដែលថាមិនបានលើកមកពិភាក្សាដេញដោលដោយអស់លោក លោកស្រីចៅក្រមនោះ ។ អ៊ីចឹង ហើយសហព្រះរាជអាជ្ញាមានជំហរថា សូមឲ្យចៅក្រមពិនិត្យមើលភស្តុតាងទាំងនោះតាមវិធាន៨៧.៣ ដើម្បីឲ្យភាគីបានដឹង ។ ហើយខ្ញុំនឹងត្រឡប់ទៅលើសំណើរបស់ខ្ញុំពីខាងដំបូង គឺសិទ្ធិក្នុងការកោះហៅសាក្សី កាលណាៗសាក្សីនោះត្រូវបានសម្គាល់រួចហើយ ហើយមានកំណត់ត្រា ហើយភស្តុតាងហ្នឹងត្រូវបានកត់ត្រាជាស្រេចដែលនោះ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកតំណាងសហព្រះរាជអាជ្ញា ហើយខ្ញុំក៏សូមបំភ្លឺចំណុចមួយដែរ ថា KW-25 ហ្នឹងគឺមានទាំងពីរ ។ ទាំងឧបសម្ព័ន្ធ “ក” ហើយនិង ឧបសម្ព័ន្ធ “គ” អាចមានការភាន់ច្រឡំតាមខ្ញុំមើលពីព្រោះឯកសារថ្មីដែលយើងមានការរៀបចំចុងក្រោយនេះ គឺបានលុបចេញនូវ KW-25 ពីឧបសម្ព័ន្ធ “គ” វិញហើយ ។ បានន័យថា នៅ “គ” ថ្មីនេះ គឺមិនមានទេ ។ មិនមាន KW-25ទេ អ៊ីចឹងគឺមានតែនៅក្នុង ឧបសម្ព័ន្ធ “ក” ប៉ុណ្ណោះ ។

[១៤:២៨:៥២]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ប្រហែលខ្ញុំអាចបំភ្លឺ KW-25នេះ គឺមិនមាននៅក្នុងបញ្ជីទីបី នោះទេ នៅក្នុងចំណោមសាក្សីដែលយើងកំណត់រយៈពេលមានការផ្លាស់ប្តូរហើយ ។ ដូច្នេះ ហើយគឺយើងបានលុបចោល KW-25 ពីបញ្ជីទី៣ នោះ ។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៀតសូមជូនទៅភាគីនៃមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី តើមានអ្វីដែលត្រូវ

ចង់និយាយដែរទេ? លើកឡើងដែរទេ? នៅបញ្ជីឧបសម្ព័ន្ធ "ក" ដែលយើងលើកមកពិភាក្សានេះ ។

**លោក អាឡាំង វ៉ែនណឺ៖**

គឺថាក្រុមខ្ញុំបានឯកភាពគ្នាហើយ ហើយខ្ញុំមិនដឹងថា តើក្រុមយើងទាំងអស់នុំងវាឯកភាពគ្នាឬអត់ទេ? គឺខ្ញុំនិយាយតែពីក្រុមរបស់ខ្ញុំតែប៉ុណ្ណោះ ហើយខ្ញុំគាំទ្រទៅនឹងជំហររបស់ខាងសហព្រះរាជអាជ្ញា ។ ហើយយើងអត់មានអ្វីជាការអធិប្បាយបន្ថែមទៅលើបញ្ជីនេះទេ ។ ហើយខ្ញុំចង់ឲ្យភ្ជាប់នៅក្នុងកំណត់ត្រា គឺខ្ញុំនិយាយតំណាងឲ្យក្រុមរបស់ខ្ញុំ ដែលខ្ញុំសូមថ្លែងអំណរគុណដល់អស់លោក លោកស្រី ដែលបានឯកភាពក្នុងស្តាប់សក្ខីកម្មនូវរយៈពេលចំនួនសាមសិបប្រាំពីរម៉ោង ដែលតំណាងឲ្យខាងដើមបណ្តឹងរដ្ឋប្បវេណី ។ ពួកយើងខ្ញុំមានការពេញចិត្តចំពោះការសម្រេចបែបនេះណាស់ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ក្រុមផ្សេងទៀត បាទសូមអញ្ជើញ ។

**លោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី៖**

សូមអរគុណលោកប្រធាន ។ នាងខ្ញុំក៏សូមបញ្ជាក់ផងដែរថានាងខ្ញុំពេញចិត្តចំពោះការពិចារណាទៅលើការបន្ថែមម៉ោងទៅលើដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្រុមរបស់នាងខ្ញុំ ។ ទាក់ទងទៅនឹងចំណុចទីមួយ ហើយនិងឧបសម្ព័ន្ធ "ក" យើងបានពិនិត្យយ៉ាងប្រុងប្រយ័ត្នទៅលើសំណើ ដែលមាននៅក្នុងបញ្ជីនេះ ។ ហើយពួកយើងខ្ញុំយល់ថា សាក្សីដូចខាងក្រោមនេះ គួរតែត្រូវបានស្តាប់សក្ខីកម្ម គឺ KW-13 នេះគឺជាសាក្សីនៅក្នុងកងពិសេស ហើយធ្វើការក្នុងការចាប់ចងនៅខាងក្រៅ ។ ហើយទៅតាមការមើលរបស់ខ្ញុំ នៅក្នុងសេចក្តីថ្លែងការណ៍របស់គាត់ហ្នឹង គឺអត់មានថែងទេ ប៉ុន្តែមានការលើកឡើងថា យ៉ាងហោចណាស់គាត់បានទៅចុះចាប់ចងម្តង ជាមួយនឹងជនជាតិចិន ដែលបានចូលរួមជាមួយចិនដប់នាក់ដែលបានចូលរួមនៅក្នុងការចាប់ចងនោះ ។ ហើយជនជាប់ចោទបានធ្វើការតវ៉ាទៅលើការចាប់ចងនេះដែលធ្វើឡើងដោយកងពិសេសនៅក្នុង ស-២១ ។

សាក្សីបន្ទាប់ គឺ KW-15 ទៅតាមការមើលឃើញរបស់ខ្ញុំ គឺថាពុំមានសាក្សីណាដែលអាចផ្តល់សេចក្តីថ្លែងការណ៍ដូចគ្នាហ្នឹង KW-18 នោះទេ ។ ឥឡូវនេះខ្ញុំ KW ដែលខ្ញុំនិយាយអម្បាញ់មិញនេះទេ ឥឡូវនេះ យើងនិយាយអំពីសាក្សី KW-18 សាក្សីនេះ គួរតែត្រូវតែបានស្តាប់ ពីព្រោះក៏មានទាក់ទងទៅនឹងចម្លើយពីមុន ដែលជនជាប់ចោទបានធ្វើការសួរចម្លើយដោយខ្លួនឯងផ្ទាល់ ។ ហើយចំណុចនេះត្រូវបានជជែកតវ៉ាលើកលែងតែពីមនុស្សមួយចំនួនតែប៉ុណ្ណោះ ។ ហើយសាក្សីនេះបាននិយាយអំពីជនបរទេស

ហើយនិងអ្នកទោសសំខាន់ៗដែលគាត់បានសង្កេតមើលផ្ទាល់ ដែលពួកគេនោះត្រូវបានសួរចម្លើយ ។ ខ្ញុំយល់ថា នេះគឺជាអង្គហេតុដែលមានការតវ៉ា ។ ដូច្នេះ ខ្ញុំយល់ថា មិនមែនជាការត្រឹមត្រូវទេបើសិនជាយើងគ្រាន់តែអាននូវបទសម្ភាសន៍របស់គាត់នោះ ។ គាត់គួរតែត្រូវបានយកមកពិភាក្សាដេញដោលនៅចំពោះមុខអង្គសវនាការ ។ ដូច្នេះ ខ្ញុំសូមធ្វើសំណូមពរទៅអស់លោក លោកស្រី ដើម្បីនៅតែទុកឈ្មោះគាត់ដដែលនៅក្នុងបញ្ជីឈ្មោះសាក្សី ។ ហើយបន្ថែមពីហ្នឹងទៀត គឺនិយាយអំពីវិធីធ្វើទារុណកម្ម ដែលត្រូវបានប្រើ គឺដោយប្រើពិលនោះ ឬក៏ប្រើភ្លើងហ្វានៅក្នុងការៗធ្វើទារុណកម្ម ។ ហើយចំណុចសំខាន់បំផុតនោះ គឺចំណុចដែលគាត់ថា ជនជាប់ចោទបានធ្វើសួរចម្លើយដោយផ្ទាល់ខ្លួន ។

[១៤:៣៤:១៥]

បន្ទាប់មកទៀត គឺខ្ញុំនិយាយអំពី KW-25 សូមអរគុណលោកចៅក្រមដែលពន្យល់បញ្ជាក់បន្ថែមអំពីចំណុចលើសាក្សីនេះ ។ សាក្សីនេះ គឺជានីរសារ ហើយបានរាយការណ៍ ហើយដែលចម្លើយរបស់គាត់ហ្នឹង ត្រូវបានតវ៉ាពីជនជាប់ចោទ ។ ហើយគាត់និយាយអំពីទំនាក់ទំនងរវាងជនជាប់ចោទជាមួយនឹងថ្នាក់លើដែលមានការប្រជុំជាញឹកញាប់ ។ ហើយទៅតាមការយល់ដឹងរបស់ខ្ញុំសាក្សីនេះ មិនអាចរាយការណ៍អំពីអ្វីមានដែលមានជាខ្លឹមសារនៅក្នុងការប្រជុំនោះទេ ប៉ុន្តែគឺថាការប្រជុំនោះបានកើតមានឡើង ។ ប៉ុន្តែចំណុចត្រូវបានមានការជជែកតវ៉ាពីជនជាប់ចោទ ដូច្នេះ ខ្ញុំយល់ថា សាក្សីនេះគួរតែត្រូវបានស្តាប់ចម្លើយ ។ ហើយការអានចម្លើយពីមាត់របស់គាត់នោះ គឺមិនគ្រប់គ្រាន់ទេ ។

[១៤:៣៥:២១]

បន្ទាប់មកទៀត គឺសាក្សី CP2/6 សាក្សីនេះ គួរតែត្រូវបានយកមកពិភាក្សាដេញដោលនៅចំពោះមុខអង្គសវនាការផងដែរ ទៅលើបញ្ហានានាទាក់ទងទៅនឹងដំណើរទស្សនកិច្ច ឬក៏ការទៅជាជើងឯករបស់ជនជាប់ចោទ ។ ដែលចំណុចនេះ ត្រូវបានជនជាប់ចោទបានធ្វើការតវ៉ា ដែលសាក្សីនេះបាននិយាយថា គាត់បានធ្វើដំណើរដោយជិះឡានទៅជើងឯក ហើយនិងបានដឹងអំពីស្ត្រីដែលមានផ្ទៃពោះត្រូវបានគេដាក់ខ្នោះជើងនោះ ហើយដែលជនជាប់ចោទបានតវ៉ាថា មិនមានរឿងហេតុបែបនោះកើតឡើងទេ ។

បន្ទាប់មកទៀត គឺទាក់ទងទៅនឹង KW28 សាក្សីនេះ គឺគួរឲ្យចាប់អារម្មណ៍ចំពោះអង្គហេតុនិងការពិតទាក់ទងទៅនឹងថ្នាំពុល និងទំនាក់ទំនងរបស់គាត់ជាមួយនឹងខ្មែរក្រហមដែលបានចេញបញ្ជាឲ្យគាត់ ហើយគាត់ត្រូវគោរពតាមបញ្ជានោះ ហើយនិងអ្វីដែលគាត់បានធ្វើបន្ទាប់ពីខែមករា ឆ្នាំ៧៩ ។

ហើយដែលមានការបន្តមកទៀត ក៏ប៉ុន្តែ ខ្ញុំដឹងហើយថា គឺអំពើអស់ទាំងហ្នឹង គឺវាស្ថិតនៅខាងក្រៅយុត្តាធិការរបស់អង្គជំនុំជម្រះនេះ ។ ក៏ប៉ុន្តែ អត្តចរិតរបស់ជនជាប់ចោទ ដែលនៅតែធ្វើឫកថា នៅតែមានការភ័យខ្លាចចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ហើយនៅតែបន្តគោនយោបាយរបស់គាត់ ។ ហើយសាក្សីនេះ អាចនិយាយអំពីអត្តចរិតរបស់ជនជាប់ចោទនេះបាន ដែលថាជនជាប់ចោទបានបញ្ជាធ្វើការចាប់ចង និងការធ្វើទារុណកម្មជាដើម ។ ដូច្នេះខ្ញុំយល់ថា សម្រាប់ស្ថានភាពបែបនេះ និងរឿងហេតុដែលជនជាប់ចោទបានលើកមកនិយាយប្រាប់នៅពេលនេះ គឺមិនអាចចៀសផុតពីអ្វីដែលគាត់និយាយថា គាត់មិនអាចធ្វើអ្វីបានក្រៅពីធ្វើកិច្ចការរបស់គាត់ ។ ក៏ប៉ុន្តែ អ្វីដែលគាត់ធ្វើនោះ គឺបន្តហួសពីខែមករា ឆ្នាំ៧៩ មកទៀត ។ ដូច្នេះ រឿងរបស់គាត់ហ្នឹង មិនមែនជាអ្វីជាឲ្យយើងជឿនោះទេ ។

[១៤:៣៨:០៤]

បន្ទាប់មកទៀតខ្ញុំនិយាយអំពីសាក្សី CP2.4 សាក្សីនេះក៏គួរតែត្រូវបានស្តាប់ចម្លើយផងដែរនៅក្នុងអង្គសវនាការ គាត់គឺសាក្សីតែម្នាក់គត់ដែលនិយាយអំពីស្ថានភាពរបស់បុគ្គលិកនៅស-២៤ ហើយទាក់ទងទៅនឹងភស្តុតាងក្នុងការបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍នៅស-២៤ ។ ដែលចំណុចនេះ វាទាក់ទងផងដែរ ទៅនឹងស្ថានភាពរបស់បុគ្គលិកនៅទីនោះ ហើយគាត់គឺជាសាក្សីតែមួយគត់ ដែលថាគាត់ហ្នឹងមិនដែលត្រូវបានសួរលម្អិត ។ ដូច្នេះ គឺព័ត៌មាននោះ មិនគ្រប់គ្រាន់ព័ត៌មាននៅក្នុងកិច្ចសម្ភាសន៍របស់គាត់នោះ មិនត្រឹមត្រូវ មិនគ្រប់គ្រាន់ទេ ។ ពីព្រោះបើតាមខ្ញុំយល់ គឺមានតែមួយប្រយោគតែប៉ុណ្ណោះ ។ ហើយគាត់និយាយអំពីបុគ្គលិកជាងម្កៃគួរដែលត្រូវពេទ្យផងដែរនោះ ដែលត្រូវបានគេបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍នោះ ។ ដូច្នេះ សាក្សីនេះ គួរតែត្រូវបានសួរចម្លើយ និងធ្វើការពិភាក្សាដេញដោលនៅចំពោះមុខអង្គសវនាការ ដើម្បីឲ្យគាត់ផ្តល់ព័ត៌មានលម្អិតបន្ថែមទៀត ។

ដូច្នេះ អ្វីដែលយើងខ្ញុំបានលើកឡើងហ្នឹង គឺបានលើកឡើងអស់ហើយ ហើយក្រៅពីនេះ យើងខ្ញុំបានឯកភាពទៅសាក្សីដទៃទៀត ដោយគ្រាន់អាននូវសេចក្តី-- នូវកិច្ចសម្ភាសន៍របស់គាត់បានហើយដូចជាហើយ សាក្សី CP2.10 ជាដើម ដែលអាចផ្តល់រូបថតទាក់ទងទៅនឹងការរៀបការនោះ ។ ហើយគឺយើងខ្ញុំឯកសារភាពទៅនឹងចំណុចផ្សេងៗទៀត ទាក់ទងទៅនឹងសាក្សីដែលគួរតែយកសេចក្តីសម្ភាសន៍របស់គាត់មកអាននៅក្នុងអង្គសវនាការបានហើយ ។ មតិយោបល់របស់ក្រុមខ្ញុំមកដល់ពេលនេះ គឺទាក់ទងទៅនៅឧបសម្ព័ន្ធ“ក” ហើយខ្ញុំសូមឈប់នៅត្រឹមនេះ ដើម្បីឲ្យក្រុមផ្សេងទៀតគាត់ចូលរួម ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី ។ សូមក្រុមបន្តទៀត ក្រុមបី ។

**លោក គឹម ម៉េងឃី៖**

សូមគោរពលោកប្រធាន! ក្នុងនាមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ពួកយើងមិនមានសេចក្តីជំទាស់ទៅនឹងការលើករបស់សហព្រះរាជអាជ្ញាទេ ចំពោះការដែលដាក់បញ្ចើ ហើយនិង ឬក៏ឰ្យរឈ្មោះសាក្សីមួយចំនួនសិន នៅក្នុងការកោះហៅឲ្យចូលមកដេញដោលនេះ ។ ក៏ប៉ុន្តែ យើងស្នើសុំអស់លោក លោកស្រីចៅក្រមទាំងអស់ ដូចជាករណីដែលសាក្សីរបស់ក្រុមដើមបណ្តឹងរដ្ឋប្បវេណីក្រុមបីដែរដែលធ្លាប់ដាក់ជូនអង្គជំនុំជម្រះម្តងហើយ គឺថា ដោយខាងជនជាប់ចោទ គាត់ក៏ទទួលស្គាល់អំពីសក្ខីកម្មរបស់សាក្សីទាំងអស់នោះ ។ អ៊ីចឹងវាមិនចាំនៅក្នុងការកោះហៅទេ ក៏ប៉ុន្តែបើសិនជាក្នុងករណីដែលសក្ខីកម្មដែល ឬក៏សាក្សីទាំងអស់ ដែលត្រូវកោះអញ្ជើញ ឬក៏ត្រូវលុបនេះ មានសារប្រយោជន៍នៅក្នុង ឬក៏មានការជំទាស់ពីខាងមេធាវីការពារ ឬក៏ខាងជនជាប់ចោទ ។ សាក្សីនោះគួរតែមានសិទ្ធិចូលមកធ្វើការដេញដោលដើម្បីជាប្រយោជន៍នៃសវនាការ ហើយដើម្បីជាការឆ្លុះបញ្ចាំងនូវអ្វីដែលវាបានកប់អស់រយៈពេលសាមសិបបីឆ្នាំមកហើយ ។

នៅក្នុងសវនាការថ្ងៃនេះ យើងអាចឃើញថា ជនជាប់ចោទគាត់មានសិទ្ធិបង្ហាញនូវសេចក្តីលោកស្តាយវិប្បដិសារីរបស់គាត់ ។ ក៏ប៉ុន្តែ យើងក៏មិនបដិសេធថាសាក្សីមួយចំនួន មិនមានវិប្បដិសារី និងការសោកស្តាយរបស់គាត់បានដែរ ។

ដូច្នេះ តាំងមានឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី និងជនរងគ្រោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីយើងខ្ញុំ យើងខ្ញុំសូមគាំទ្រចំពោះការលើកឡើងរបស់សហព្រះរាជអាជ្ញា ។ ក៏ប៉ុន្តែ ក្នុងករណីដែលលោកលោកស្រីសម្រេចថាដកឈ្មោះ ឬក៏មានករណីដែលដកឈ្មោះ ។ យើងថាមិនគួរមានការលុបឈ្មោះ ឬក៏ដកឈ្មោះក្នុងការធ្វើសក្ខីកម្មទេ ក៏ប៉ុន្តែ គួរតែកាត់បន្ថយនូវពេលវេលាជាអតិបរមាតាមដែលអាចទៅបាន ។ សូមអរគុណ ។

[១៤:៤២:៥៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញក្រុមបន្តទៀត ក្រុមមេធាវីក្រុមបួនបាទ អូ៎! ចឹងក្រុមបួន ។

**លោក គង់ ពិសី៖**

សូមអរគុណបាទ ។ សូមគោរពលោកប្រធាន និងលោក លោកស្រីចៅក្រមក្នុងអង្គប្រជុំជាទីគោរព ។ ចំពោះខ្ញុំបាទជាតំណាងឲ្យមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបួន មិនមានជាចំណោទអីច្រើនពេកទេ ។ ប៉ុន្តែ គ្រាន់តែខ្ញុំបាទសូមបញ្ជាក់ថា ទីមួយគឺខាងក្រុមខ្ញុំបាទ សូមគាំទ្រនូវការលើកឡើងរបស់សហព្រះរាជអាជ្ញា ។ ហើយនិងទីពីរ ខាងលោកមេធាវីក្រុមមួយ ក្រុមពីរ ក្រុមបីផងដែរ ។ ហើយខ្ញុំបាទសូមបញ្ជាក់ជូនថា អ្វីដែលខ្ញុំបាទចង់បញ្ជាក់គឺសាក្សី KW-12, KW-13, KW-14, KW-18, KW-19 ជាមួយនឹង KW-28 នេះក៏ជាគំនិតផ្ទាល់របស់ក្រុមខ្ញុំបាទ មិនខុសពីក្រុមលោក ក្រុមទីបីអំមិញទេ ។ គឺយើងចង់ឲ្យមានការមកឆ្លើយបំភ្លឺ ទោះមានការឯកភាព ឬមាននៅក្នុងកំណត់ហេតុឆ្លើយបំភ្លឺចំពោះមុខលោកចៅក្រមស៊ើបអង្កេតក៏ដោយ ។ ហើយក៏យើងកំណត់តែវគ្គខ្លីៗ ឬលោកចៅក្រមកំណត់ពេលវេលាខ្លីទៅបានហើយ កុំវាអូសបន្លាយពេលវែង ។

នេះគឺសបញ្ជាក់ ដើម្បីឲ្យឃើញការនិយាយផ្ទាល់មាត់នូវសាក្សីរស់ទាំងនោះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវីក្រុមបួន ។ ចុះខាងភាគីមេធាវីការពារវិញ មានយោបល់អីទេ?

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន ។ ចំពោះរូបខ្ញុំជាមេធាវីការពារខ្ញុំសូមឯកភាពទាំងស្រុងទៅលើបញ្ជីឈ្មោះសាក្សីដែលស្នើឲ្យដកចេញពីបញ្ជីឈ្មោះសាក្សីនេះ ។ ប៉ុន្តែ ខ្ញុំសូមតែមួយទេ គឺដប់ប្រាំពីរនាក់ គឺខ្ញុំសូមឯកភាព គឺខ្ញុំសូមដកតែមួយចេញទេ ន៎ែ ដកលេខរៀងទី១៧ គឺ *រ៉ាអូល ម៉ាកហ្សេណា* សូមឲ្យទុកគាត់នៅជាសាក្សីដដែល ។ នេះជាសំណូមពរខាងខ្ញុំ ហើយសំណូមពរខាងខ្ញុំដែលទុកឲ្យនៅ *ម៉ាករ៉ាអូល ហ្សេណា* នៅជាសាក្សីដដែល ព្រោះខ្ញុំយល់ឃើញថា លោក *ម៉ាក រ៉ាអូលហ្សេណា* គាត់ជាអ្នកស្រាវជ្រាវឧក្រិដ្ឋកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការស្រាវជ្រាវរបស់គាត់នេះ គឺគ្រប់គុកទាំងអស់មួយរយ-- ដែលខ្ញុំមើលឯកសាររបស់គាត់ គឺ១៩៦ គុក ។ គាត់ស្រាវជ្រាវខ្វះតែបីបួនគុកទេ ក្នុងស្រុកបាភ្នំ ខេត្តព្រៃវែង ដែលគាត់ខ្វះចន្លោះ ។

អ៊ីចឹង ឧក្រិដ្ឋកម្មគុកណា ក៏គាត់ស្រាវជ្រាវដែរ លើវិធីគុកណាមួយធ្វើ របៀបម៉េចៗ ។ គឺថាយើងប្រៀបធៀបរវាងគុកទាំង១៩៦ ហ្នឹង មកនឹង ស-២១ តើវាដូចគ្នាទេ? ឬមួយក៏ ស-២១ ហ្នឹងវាធ្ងន់

ធូរជាងគេ? វាអាក្រកអាក្រីជាងគេ? ឬមួយក៏គុកដទៃទៀតនោះ វាក្រក់ដូចតែស-២១ ដែរ? ហើយយ៉ាងម៉េច? ហើយគុកមួយសម្លាប់ប៉ុន្មាននាក់? របៀបធ្វើទារុណកម្មយ៉ាងម៉េច? អីយ៉ាងម៉េច? គឺគាត់បានស្រាវជ្រាវគ្រប់ទាំង១៩៦គុក មានក្នុងបញ្ជីរបស់គាត់ ។ បញ្ជីរបស់គាត់មួយកម្ពស់ណាណី ។

ដូច្នេះខ្ញុំយល់ថាសាក្សីរូបនេះវាជាសាក្សីសំខាន់មួយ សម្រាប់ឲ្យយើងប្រៀបធៀបឲ្យឃើញមុននឹងសម្រេចថាគាត់នឹងវា ស-២១ ហ្នឹងវាអាក្រក់ជាងគេបែបណា? ក៏សូមប្រៀបធៀបឲ្យឃើញថា--ដោយ *រ៉ាអូលហ្សេណា* គាត់ជាអ្នកស្រាវជ្រាវហ្នឹង គឺគាត់មកបំភ្លឺបាន ។ នេះជាសំណូមពររបស់ខ្ញុំ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

[១៤:៤៧:៣៣]

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនិយាយសាជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណដល់អង្គសវនាការ និងភាគីដែលទទួលយកការផ្លាស់ប្តូររបៀបវារៈនៅពេលនេះ ដែលអនុញ្ញាតឲ្យខ្ញុំចូលរួមនៅក្នុងកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃនេះ ។ ហើយប្រសិនបើខ្ញុំសូមបន្ថែមចំណុចបន្តិច គឺគេបានលើកឡើងអំពីបញ្ហាផ្សេងៗហើយគឺថាពេលខ្លះទៅយើងមិនធ្វើការកែប្រែរបៀបវារៈរបស់តុលាការអន្តរជាតិផ្សេងៗនោះទេ។

ដូច្នេះ ខ្ញុំសូមអរគុណ ហើយខ្ញុំសូមធ្វើការគាំទ្រនូវអ្វីដែលលោក ការ សាវុត្ថ បានលើកឡើងទាក់ទងទៅនឹង *រ៉ាអូល ម៉ាកហ្សេណា* ហើយមានការស្នើឡើងទៅលើចំណុចនេះ ។ វាបង្ហាញយ៉ាងច្បាស់ថានៅពេលនេះ នៅពេលដែលសហព្រះរាជអាជ្ញាបានធ្វើការដេញដោលសាក្សីជំនាញមួយ គឺលោក *ក្រេក អេតធេសាន់* ។ ហើយនៅសាក្សីទីពីរដែលជា *ដេវីត ឆេនដ៍ល័រ* នោះ គឺខ្ញុំគិតថាវាមិនភាពយុត្តិធម៌ក្នុងការរារាំងមេធាវីការពារក្តីក្នុងការកោះហៅ សាក្តីអ្នកជំនាញចូលមកផ្តល់សក្ខីនោះទេ ។ ប៉ុន្តែយ៉ាងណាក៏ខ្ញុំជឿថាយើងអាចយល់ស្របទាំងស្រុងទៅចំណុចដែលថា លោក *រ៉ាអូល ម៉ាកហ្សេណា* គឺគួរបញ្ចូលក្នុងឧសម្ព័ន្ធ "គ" ។ បានន័យថាយើងបន្ថយរយៈស្តាប់សក្ខីកម្ម យើងមិនបាច់ស្តាប់គាត់ក្នុងរយៈបីថ្ងៃ ឬក៏ពីរថ្ងៃនោះទេ ។

[១៤:៤៩:៤៣]

យើងអាចបន្ថយរយៈពេលគាត់ ដូចលោក *ដេវីត ឆេនដ៍ល័រ* ផងដែរ ។ ហើយយើងធ្វើការស្តាប់សក្ខីលោក *រ៉ាំអូល* នេះក្នុងរយៈពេលមួយថ្ងៃ ។ ហើយចំពោះសាក្សីផ្សេងៗទៀត ខ្ញុំមានការភ្ញាក់ផ្អើលបន្តិចដែរ នៅពេលមានការផ្លាស់ប្តូរជំហររវាងដើមបណ្តឹងរដ្ឋប្បវេណី ។ ប្រសិនបើយើងធ្វើការបញ្ចូលបូកសរុបសាក្សីដែលគាត់ចង់រក្សាទុកនោះ គឺខ្ញុំជឿថា គឺចំណុចនេះ គឺវាហាក់ដូចជាយើងចំណាយពេលច្រើន ។ ហើយការដែលយើងរៀបចំបញ្ជីនេះ គឺយើងបានគិតអំពីថាតើសាក្សីទាំងអស់នេះគឺមានភាពចាំបាច់ដែរឬទេក្នុងការផ្តល់ភស្តុតាង ដែលគាត់ត្រូវតែមកផ្តល់នោះ?

ដូច្នេះ ខ្ញុំហាក់ដូចជាមិនសូវយល់ច្បាស់លាស់អំពីជំហរ ឬក៏ជំហរគាត់ផ្សេងៗគ្នា ក្នុងចំណោមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ ហើយខ្ញុំក៏មិនយល់ផងដែរ ទៅលើជំហររបស់សហព្រះរាជអាជ្ញា ។ យើងគួរតែដកចេញសាក្សីនេះ? ឬក៏យើងមិនដកចេញ? យើងត្រូវតែមានកង់មួយដែលច្បាស់លាស់ ឬយន្តការមួយដែលច្បាស់លាស់ ។ ហើយយើងគួរតែលើកឡើងថា យើងទទួល ឬក៏យើងមិនទទួល? ហើយថាតើយើងទទួលយកបញ្ជីនេះ តើវាមានប្រយោជន៍យ៉ាងម៉េច? ហើយគឺខាងមេធាវីការពារក្តីបានលើកឡើងហើយ ។ ហើយនៅក្នុងរបៀបវារៈទីពីរ នៅពេលដែលយើងបានទទួលយកសាក្សីដែលថាគាត់មិនចាំបាច់មកផ្តល់សក្ខីកម្មបានន័យថាមេធាវីការពារក្តីមិនមានលទ្ធភាពដេញដោលទៅលើសាក្សី ហើយមេធាវីការពារក្តីមិនអាចមានលទ្ធភាពក្នុងការដេញដោលនិងតទល់ ។

ដូច្នេះ ខាងមេធាវីការពារក្តីទេ ដែលគាត់បាត់បង់សិទ្ធិរបស់គាត់ច្រើន ។ ប៉ុន្តែ យ៉ាងណាក៏ដោយ គឺមេធាវីការពារក្តីទទួលយកទៅលើការដកសាក្សី ហើយយើងទទួលយកតែលើចំណុចទាំងអស់នេះ ។ មេធាវីការពារក្តីមានឆន្ទៈក្នុងការទទួលយកគ្រោះដែលថា ទោះបីយើងមិនកោះហៅសាក្សីនោះក៏ដោយ ។

ប៉ុន្តែ មេធាវីការពារក្តីសូមធ្វើការស្នើសុំថា យើងទទួលសក្ខីកម្មទាំងឡាយដែលយើងបានរៀបចំឡើងនោះ ។ ដូច្នេះ យើងមិនចាំបាច់កោះហៅសាក្សីនោះទេ ។ ដូច្នេះ មេធាវីការពារក្តី គឺយើងរក្សាសិទ្ធិក្នុងការពិភាក្សាដេញដោលទៅលើសក្ខីនិងចម្លើយរបស់សាក្សីទាំងអស់នោះ ។ ឧទាហរណ៍ថា ខ្ញុំដូចជាអត់ចាំច្បាស់លាស់ទេ នៅពេលដែលសាក្សីនិយាយអំពីកញ្ចប់ឈាមម្តៅទៅសាមសិបមេធាវីការពារក្តី គឺគាត់រក្សាសិទ្ធិក្នុងជំទាស់ទៅលើករណី ។ នេះជាអ្វីដែលហៅរក្សាសិទ្ធិ ។

[១៤:៥៣:១១]

ហើយថាតើយើងនឹងផ្លាស់ប្តូរការជំនុំជម្រះទាំងមូល បើសិនជាយើងធ្វើដូច្នេះនៅចំពោះការដកសាក្សី ។ មេធាវីការពារក្តី គឺយើងយល់ស្របទៅលើជំហររបស់លោកអង្គសវនាការ ។ ហើយមេធាវីការពារក្តីសូមស្នើសុំដាក់ឈ្មោះលោក *វ៉ាអូល ម៉ាកហ្សេណា* ទៅក្នុងឧបសម្ព័ន្ធ "គ" វិញ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវីដែលបានបង្ហាញនូវទស្សនរបស់លោកនៅក្នុងរបៀបវារៈនៃទីមួយនេះ ។ អស់លោក លោកស្រីចៅក្រមមានអ្វីត្រូវកត់សម្គាល់ទេ អំពីចំណុចរបៀបវារៈទីមួយនេះ?

បើមិនមានទេគឺយើងឈានចូលទៅដល់របៀបវារៈទីពីរ ហើយរបៀបវារៈទីពីរនេះមានការពាក់ព័ន្ធផ្ទាល់ទៅនឹងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរតែប៉ុណ្ណោះ ។ ចំណែកឯក្រុមផ្សេងទៀតហ្នឹងមិនមានការពាក់ព័ន្ធទៅលើនឹងបញ្ហាត្រង់របៀបវារៈទីពីរនេះទេ ឬក៏របៀបវារៈ "ខ" នេះទេ ឧបសម្ព័ន្ធ "ខ" នេះទេ ។

នៅក្នុងរបៀបវារៈនេះ គឺបញ្ជីឈ្មោះសាក្សីដែលអង្គជំនុំជម្រះស្នើសុំឲ្យមានការបំភ្លឺ ។ ទីមួយថាតើមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរនៅតែរក្សាជំហរក្នុងការស្នើសុំកោះហៅសាក្សីដែលមានឈ្មោះ រហស្សនាម CP2/1, CP2/2 ហើយនិង CP2/3 នេះដដែល ឬក៏យ៉ាងណា? ហើយបើទុកវិញ តើមានមូលហេតុអ្វី? សូមបង្ហាញអំពីភាពពាក់ព័ន្ធនៃសាក្សីទាំងបីខាងនេះទៅនឹងអង្គហេតុដែលត្រូវអញ្ជើញគាត់មកផ្តល់សក្ខីកម្ម ។

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្ត៖**

សូមអរគុណលោកប្រធានលោក លោកស្រីចៅក្រម។ ជំហររបស់យើងខ្ញុំទាក់ទងទៅនឹងឧបសម្ព័ន្ធ "ខ" គឺដូចតទៅ គឺយើងនៅចង់រក្សាសាក្សី CP2/1 ហើយយើងដក CP2/2 និង CP2/3 ហើយចំពោះសាក្សី CP2/1 នេះ គឺគាត់នឹងបង្ហាញអំពីការផ្លាស់ប្តូរផ្សេងៗរវាងកងពល៥០២ ហើយគាត់ក៏នឹងផ្តល់ភស្តុតាងរយៈពេលផ្សេងៗនៅក្នុងសម័យខ្មែរក្រហម ។ ហើយគាត់នឹងបង្ហាញអំពីរយៈពេលដែលជនជាប់ចោទនៅជាមួយនឹងCP2/1 ហើយគាត់នឹងផ្តល់ព័ត៌មានទៅដល់អង្គសវនាការ និងភាគីថាគាត់គួរតែចាកចេញ ប៉ុន្តែ នៅតែជាមួយខ្មែរក្រហម ហើយគាត់ជឿទៅលើខ្មែរក្រហម ។ ដូច្នេះហើយយើងចង់ស្តាប់សាក្សី CP2/1 ហើយចំពោះ CP2/2 និង CP2/3 គឺយើងសុំដក ។

**ប្រធានអង្គជំនុំ៖**

ឥឡូវចូលនៅក្នុងរបៀបវារៈទីបី ដោយសាររបៀបវារៈទីពីរនេះ មានតែក្រុមពីរទេ ដែលជាម្ចាស់សំណើ ហើយឥឡូវហ្នឹងគាត់បានសុំដកនូវសាក្សី ឈ្មោះសាក្សីចំនួនពីរហើយពីបញ្ជីដែលគាត់បានស្នើ ហើយនៅសល់តែមួយទេ ហើយគាត់បានបង្ហាញហេតុរួចហើយ ។

នៅក្នុងរបៀបវារៈទីបី ឬក៏ឧបសម្ព័ន្ធ “គ” នេះ គឺអង្គជំនុំជម្រះសូមជម្រាបដល់ភាគីថា អង្គជំនុំជម្រះនឹងប្រើគោលការណ៍ សាក្សីម្នាក់ត្រូវចំណាយពេលវេលាអតិបរិមាក្នុងការធ្វើសក្ខីកម្មមួយថ្ងៃហើយ និងកាត់បន្ថយនៅពេលវេលាដែលបានស្នើឡើងសម្រាប់ធ្វើសក្ខីកម្មរបស់សាក្សីមួយចំនួនដូចខាងក្រោមនេះ៖

សាក្សី KW-10 ពីមុនគឺយើងបានរៀបចំគម្រោងផែនការ គឺពីរថ្ងៃកន្លះ ។ ឥឡូវនេះ យើងសូមបន្ថយ គឺគម្រោងមកនៅត្រឹមមួយថ្ងៃ ។

ដេវីដ ឆេនដ័ល័រ ពីដើមគឺគម្រោងពីរថ្ងៃ ។ ឥឡូវកាត់បន្ថយឲ្យនៅមួយថ្ងៃ ។ ហើយ KW-23 ពីមួយថ្ងៃ មកនៅត្រឹមកន្លះថ្ងៃ ។ ហើយ CP2/5 ពីមួយថ្ងៃ មកនៅត្រឹមកន្លះថ្ងៃ ។

ដោយឡែក KW-34 និង ហ្វ្រង់ស្វ័រ ស៊ីរ៉ូនី វាលបូ រយៈពេលរួម គឺមុនបួនថ្ងៃ ឥឡូវយកមកធ្វើទាំងពីរនាក់ហ្នឹង តែមួយថ្ងៃនេះ ។ យើងបន្ថយពីបួនថ្ងៃ មកនៅធ្វើស្តាប់សក្ខីកម្មតែមួយថ្ងៃទេ ។ ហើយលើកលែងតែសាក្សី KW-08 និង KW-09 ដែលត្រូវស្តាប់ចម្លើយគាត់ ឬក៏ស្តាប់ការផ្តល់សក្ខីកម្មរបស់គាត់ រយៈពេលពីរថ្ងៃសម្រាប់សាក្សីម្នាក់ៗ ។ អ៊ីចឹងពីរនាក់ហ្នឹងគឺត្រូវចំណាយពេលរហូតដល់បួនថ្ងៃ ។

សូមភាគីទាំងអស់ មានការមតិពាក់ព័ន្ធជាមួយនឹងបញ្ហាដែលលើកឡើងនៅក្នុងរបៀបវារៈទីបីនេះ ។ ហើយខ្ញុំក៏កត់សម្គាល់ឃើញផងដែលថា មតិជាច្រើនកន្លងមកនេះ សូម្បីតែការស្នើសុំឲ្យមានការដាក់ចូលនូវរបៀបវារៈនៃការស្តាប់សក្ខីកម្មចំពោះសាក្សីមួយចំនួន ដែលបានស្នើដកក៏ដោយ ក៏ភាគីហាក់ដូចជាមានការឯកភាពគ្នា ក្នុងការយល់ស្របថា ត្រូវមានតែកាត់បន្ថយ ។ អ៊ីចឹងឯកភាពជារួម គឺការកាត់បន្ថយពេលវេលាក្នុងការធ្វើសក្ខីកម្ម ។ អានេះខ្ញុំឃើញជាកត់សម្គាល់ជារួម ហើយឥឡូវនេះគឺយើងស្នើកាត់បន្ថយរយៈពេលអំឡុងពេលសម្រាប់ធ្វើសក្ខីកម្ម ដូចដែលយើងបានរៀបរាប់អ៊ីចឹង ។

សូមអញ្ជើញលោកមេធាវីហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន តើលោកអាចនិយាយឡើងវិញទេនៅសាក្សីចុងក្រោយពីរនាក់ទៀត? តើសាក្សីចុងក្រោយពីរនាក់ទៀតហ្នឹង ជានរណាគេ? គឺខ្ញុំស្តាប់អត់ទាន់ទេ សូមអរគុណ ។

**លោកស្រី ស៊ីលឃី ស្នូតហ្សឺនស្ដី៖**

ហើយខ្ញុំក៏អត់បានស្ដាប់ដែរ នៅ KW-10 នោះ តើជានរណាគេដែរ? អរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អំមិញយើងបានជជែកគាត់ហើយ ថាយើងគោរពគោលការណ៍មួយ គឺយើងឯកភាពការក្នុងការប្រើនៅរហស្សនាម ។ ប៉ុន្តែ ដោយសារភាពច្បាស់លាស់ ហើយថ្ងៃនេះជាសម្ងាត់ផង អ៊ីចឹងយើងក៏អាចជម្រាបបានថា KW-08 និង KW-09 គឺជាសាក្សីពីររូបដែលយើងមានបំណងក្នុងការកោះហៅធ្វើសវនាការកន្លងមកហើយ ដែលយើងអាក់ខានមិនបានវិញ គឺ ម៉ម ណៃ ជាមួយនិង ហ៊ឹម ហ៊ុយ ដោយលក្ខណៈសម្បត្តិនៃ ម៉ម ណៃ ហៅ ចាន់ ហើយនិង ហ៊ឹម ហ៊ុយ ដោយសារលក្ខណៈសម្បត្តិនៃសាក្សីពីរនាក់ ដែលយើងប៉ុនប៉ងធ្វើលើកមុននោះ គឺមានអង្គហេតុច្រើន អង្គហេតុតាំងពីម-១៣មក អ៊ីចឹងហើយបានជាយើងគណនាទៅ ឃើញថាមានត្រូវការចំណាយពេលវេលាក្នុងការសាកសួរនេះ ។ ហើយចំណែកឯ KW-10 យើងប្រើអំឡុងពេលមួយថ្ងៃ គឺយើងប្រាប់ហើយ គឺពីពីរថ្ងៃកន្លះមកមួយថ្ងៃ ។ ត្រូវការយើងប្រាប់ឈ្មោះទេ? អំមិញហើយប្រើរហស្សនាម ព្រោះមានការខ្លាចពាក់ព័ន្ធជាមួយលាក់ការណ៍ យើងគួរតែត្រូវប្រើប្រាស់អំមិញ គឺអាចដោយសារតែមានបញ្ហាចង់បញ្ជាក់ឲ្យច្បាស់ ។ នេះ គឺសាក្សីដែលមានសារសំខាន់ នៅក្នុងដំណើរការនៃដំណើរការក្ដី ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ យើងព្យាយាមក្នុងការកាត់បន្ថយពេលវេលា តាមគោលការណ៍នៃការពន្លឿននៅក្នុងកិច្ចសវនាការរបស់យើង ។ ហើយសូមមើលឯកសារ ។

សូមអញ្ជើញសហព្រះរាជអាជ្ញា ។

**លោក វីលៀម ស្មីត៖**

លោកប្រធាន យើងខ្ញុំឯកភាពទៅនឹងការស្នើឡើង ។ ចំណែកទាក់ទងទៅនឹងសាក្សី KW-10 ហ្នឹងគាត់ជាមនុស្សសំខាន់ណាស់នៅក្នុងរឿងក្ដីនេះ ។ ដូច្នេះ ខ្ញុំយល់ថា នៅពេលដែលចៅក្រមស៊ើបសួរនោះខ្ញុំយល់ថា មិនអាចគ្រាន់តែស៊ីពេលពីរបីម៉ោងទេ ប្រហែលអាចជាស៊ីពេលយ៉ាងហោចណាស់ក៏មួយថ្ងៃកន្លះដែរ ។ ក្រៅពីហ្នឹង គឺថាយើងខ្ញុំឯកភាពទាំងស្រុងទៅនឹងសំណើរបស់លោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អរគុណសហព្រះរាជអាជ្ញា ។ សូមអញ្ជើញទៀត សូមអញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ ក្រុមមួយៗមានយោបល់យ៉ាងម៉េច លើបញ្ហាកាត់បន្ថយពេលវេលាក្នុងការស្តាប់សក្ខីកម្មដែលមាននៅក្នុងចំណុចទីបី ឬក៏ឧបសម្ព័ន្ធ “គ”នេះ?

**លោក អាឡាំង វ៉ែនណឺ៖**

លោកចៅក្រម ខ្ញុំអត់មានមតិអីទេ សូមអរគុណ គឺឯកភាពទាំងស្រុង ។

**លោកស្រី ស៊ីលយី ស្ទូតហ្សីនស្គី៖**

មតិរបស់យើងខ្ញុំ គឺទាក់ទងទៅនឹងសាក្សី KW-10 យើងខ្ញុំសូមបញ្ចេញនូវមតិដូចខាងក្រោមនេះ៖

ដោយសារគាត់ គឺជាសាក្សីដែលសំខាន់ ហើយដែលជនជាប់ចោទបានធ្វើការតវ៉ាទៅលើសក្ខីកម្មពីមុនរបស់គាត់នោះ ។ ដូច្នេះ ខ្ញុំយល់ថា គាត់នឹងអាចត្រូវការពេលវេលាច្រើនជាងនេះ ដើម្បីឲ្យយើងធ្វើការពិភាក្សាដេញដោលទៅលើគាត់ ។ ហើយខ្ញុំមិនគាត់ថា រយៈពេលមួយថ្ងៃកន្លះហ្នឹង គ្រប់គ្រាន់ឬ ក៏អត់ទេ? ពីព្រោះបើយើងធ្វើការសួរដេញដោលច្រើន ព្រមទាំងពីជនជាប់ចោទទៀតនោះ គឺយើងអាចធ្វើការចំណាយត្រូវការពេលច្រើនជាងនេះ ។

[១៥:០៦:០៧]

ទាក់ទងទៅនឹងសាក្សី KW34 គឺលោកចៅក្រមបានសម្រេចចិត្តកាត់បន្ថយសម្រាប់ការផ្តល់សក្ខីកម្មហ្នឹង រហូតដល់តែមួយថ្ងៃទេ មែនទេលោកប្រធាន?

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៌៖**

ត្រឹមត្រូវហើយ អង្គជំនុំជម្រះបានធ្វើការសម្រេចចិត្តថា ជាមួយសាក្សី KW34 ហើយនិងហ្វ្រង់ស្វ័រ ស៊ីរ៉ូនី វាលបូ ដែលទាំងពីរនាក់នេះនឹងផ្តល់សក្ខីកម្មរួមគ្នា ហើយពេលវេលាសរុបសម្រាប់អ្នកទាំងពីរនេះ គឺមួយថ្ងៃ ។ តើច្បាស់នៅ?

**លោកស្រី ស៊ីលយី ស្ទូតហ្សីនស្គី៖**

សូមអរគុណចំពោះការបញ្ជាក់ឡើងវិញនេះ ។ ខ្ញុំសូមលើកសំណូមពរទាក់ទងទៅនឹងអ្នកជំនាញទាំងពីរនាក់នេះ សាក្សីដែលជាអ្នកជំនាញទាំងពីរនាក់នេះ ដែលបានធ្វើការពិនិត្យទៅលើជនជាប់ចោទ ខ្ញុំយល់ថា គឺជាការសំខាន់ណាស់ ដើម្បីបំភ្លឺចំណុចទៅលើជនជាប់ចោទ និងការធ្វើការវាយតម្លៃទៅលើអ្វី

ដែលគាត់និយាយ និងអាប្បកិរិយារបស់គាត់។ ដូច្នេះ ខ្ញុំយល់ថា រយៈពេលមួយសម្រាប់គាត់ទាំងពីរនោះដូចជាវាខ្លីបន្តិចហើយ ។ ដូច្នេះ ខ្ញុំសូមស្នើថា យ៉ាងហោចណាស់សម្រាប់ពួកគាត់ទាំងពីរនេះ គឺត្រូវការស៊ីពេលប្រហែលជាមួយកន្លះ ដើម្បីឲ្យភាគីពាក់ព័ន្ធនានា មានឱកាសដើម្បីសាកសួរពួកគាត់ ។ ទាក់ទងទៅនឹងឯកសារ ដែលយើងខ្ញុំបានអាន ហើយនិងភាពជំនាញរបស់គាត់ ។ ដូច្នេះ ខ្ញុំយល់ថា ពួកគាត់អាចត្រូវការពេលវេលាច្រើនជាងនេះ ដើម្បីផ្តល់នូវសេចក្តីរាយការណ៍របស់គាត់ ។ សូមអរគុណ ។ ហើយសំណូមពរផ្សេងៗទៀត គឺថាក្រុមខ្ញុំឯកភាពទាំងអស់ ។

**លោក គីម ម៉េងឃី៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំយើងខ្ញុំ គឺមិនជំទាស់ទៅនឹងអ្វីដែលលោកប្រធានបានលើកឡើងទាំងស្រុងនៅអ្វីដែលអង្គជំនុំជម្រះបានសម្រេច ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីក្រុមបួន ។

[១៥:០៨:២៧]

**លោក ហុង គីមសួន៖**

សូមអរគុណនិងសូមគោរពលោកប្រធានម្តងទៀត។ ក្រុមទីបួនផ្នែកខាងដើមបណ្តឹងរដ្ឋប្បវេណីខ្ញុំបាទនេះ សូមគាំទ្រនូវការលើកឡើងរបស់មេធាវីក្រុមផ្សេងៗផងដែរ និងខាងសហព្រះរាជាអាជ្ញាផងដែរ ។ ជាពិសេស ខ្ញុំបាទសូមពិចារណាទៅលើសាក្សី CP2/5 សាក្សីរូបនេះ គាត់ជាដុកទ័រជំនាញខ្ញុំបាទចង់សុំឲ្យលោកប្រធាននិងក្រុមប្រឹក្សាជម្រះពិចារណាថា រយៈពេលកន្លះថ្ងៃ ខ្ញុំយល់ឃើញថាសាក្សីរូបនេះនឹងបញ្ជាក់អំពីហេតុផលទាំងឡាយទាក់ទិននឹងជនរងគ្រោះ បង្ហាញឲ្យឃើញភាពចាំបាច់ទាក់ទងជាមួយនឹងការទាមទារសំណង ឬក៏ភាពឈឺចាប់អ្វីទាំងឡាយរបស់គេ ។ ដូច្នេះ ខ្ញុំបាទគិតថាគួរតែមានរយៈពេលមួយថ្ងៃ ពីព្រោះពេលនោះ គឺខ្ញុំជឿថា មានភាគីទាំងអស់នឹងសាកសួរអំពីជំនាញរបស់គាត់ ។ ដែលខ្ញុំមានតែមួយនេះទេ បាទសូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី ។ ជាបន្តសូមអញ្ជើញមេធាវីការពារ សូមអញ្ជើញលោក ការសាវុត្ត ។

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធាន! ខ្ញុំឯកភាពទាំងស្រុងទៅតាមអ្វីដែលលោកប្រធានបានលើកឡើងថា ខ្លះត្រូវសួរមួយថ្ងៃ ខ្លះត្រូវសួរកន្លះថ្ងៃអីហ្នឹង ។ គឺខ្ញុំឯកភាពទាំងស្រុង ក៏ប៉ុន្តែ ខ្ញុំសូមណូមពរៗថា បើសួរកន្លះថ្ងៃសួរមួយថ្ងៃអី សូមលោកប្រធានបែងចែកពេលវេលាឲ្យច្បាស់លាស់ ។ ហើយក្នុងហ្នឹង មុននឹងចូលសួរដល់សាក្សីណា កន្លះថ្ងៃមួយថ្ងៃ ថាន៎! ខាងណោះ មួយក្រុមហ្នឹងត្រូវសួរប្រាំនាទី កុំឲ្យដល់ពេលគាត់សួរហើយ ចេះតែសួរទៅ លើសដល់ខ្ញុំអាអ្នកក្រោយគេអត់អីសួរ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវីដែលបានផ្តល់គំនិតដ៏ល្អៗនេះ ហើយប្រហែលជាអង្គជំនុំជម្រះមានបទពិសោធន៍នៅក្នុងដំណើរការនៃគ្រប់គ្រងសវនាការហើយ តាំងពីពេលនោះរហូតដល់ពេលកន្លងមកថ្មីៗនេះដោយសារការកំណត់ពេលវេលាវានាំឲ្យយើងមានការភាពច្បាស់លាស់ប្រាកដប្រជានៅក្នុងការដែលពន្លឿននីតិវិធី ។

សូមអញ្ជើញលោក ហ្រ្វង់ស្វ័រ រូ មានអ្វីចង់និយាយដែរទេ?

**លោក ហ្រ្វង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំគិតថា ខ្ញុំសូមឯកភាពជាមួយនឹងសហសេវិកនិងមេធាវីនៅក្នុងក្រុមនេះ ជាពិសេសគឺកញ្ញា ស្វូតហ្សីនស្គី ទាក់ទងទៅនឹងការផ្តល់សក្ខីកម្មរបស់អ្នកជំនាញ។ គឺបើសិនជាយើងមានលទ្ធភាព យ៉ាងហោចណាស់ត្រូវផ្តល់ពេលកន្លះថ្ងៃទៀតឲ្យដល់សាក្សីដែលបានស្នើឡើងដោយកញ្ញា ស្វូត ហ្សីនស្គី នោះ ។ ហើយខ្ញុំចង់និយាយបន្ថែមនៅពេលនេះថា វាអាស្រ័យទៅលើថាតើអ្នកជំនាញនេះគាត់មានឱកាស ឬក៏អត់ទេនោះ យើងខ្ញុំសូមស្នើឲ្យមានវត្តមានរបស់ *ស៊ីរ៉ូនីហ្គីលបា* ហ្នឹងឯង ឲ្យគាត់មានវត្តមាននៅក្នុងអង្គសវនាការតែម្តង មិនចាំបាច់ធ្វើការផ្តល់សក្ខីកម្មពីចម្ងាយនោះទេ ។

ទាក់ទងទៅនឹងការផ្តល់ពេលវេលាពីរថ្ងៃ សម្រាប់ឲ្យសាក្សីKW-08 និង ២ថ្ងៃ សម្រាប់KW-09 និងរយៈពេល១ថ្ងៃសម្រាប់KW-10នោះ ខ្ញុំជឿថា គឺវាមិនច្រើនពេកទេក្នុងការស្នើសុំទៅអង្គជំនុំជម្រះដើម្បីឲ្យមានឱកាសច្រើនជាងមួយថ្ងៃនេះ ដើម្បីស្តាប់នូវសក្ខីកម្មរបស់អ្នកជំនាញខាងចិត្តសាស្ត្រ។

ហើយទាក់ទងទៅនឹងលោក *ដេវីដ ឆេនដ៏ល័រ* ខ្ញុំយល់ថាគាត់គឺជាអ្នកជំនាញដ៏ឧត្តុង្គឧត្តមជាងគេដែលមាន ចំណេះដឹងជ្រាលជ្រៅជាងគេអំពីស-២១ ហើយខ្ញុំយល់ថាយ៉ាងហោចណាស់ក៏ត្រូវការពេលកន្លះថ្ងៃទៀតដែរ ដើម្បីស្តាប់សក្ខីកម្មរបស់គាត់នេះ ។ និយាយអំពីការងាររបស់គាត់ ពីព្រោះការងារ

របស់គាត់នោះគឺជាតម្រូវការបំផុតសម្រាប់យើងនិងចំណេះដឹងដ៏ជ្រាលជ្រៅរបស់គាត់អំពីស-២១ ហើយចំណេះដឹងរបស់គាត់ហ្នឹងត្រូវបានយកមកប្រើជាឯកសារយោងយ៉ាងច្រើននៅក្នុងការស៊ើបអង្កេត ។

[១៥:១៣:១៦]

ដូច្នេះ យើងត្រូវគិតថា យ៉ាងហោចណាស់យើងគួរតែត្រូវមានរយៈពេលកន្លះថ្ងៃទៀតដើម្បីឲ្យលោក *ដេវីដ ឆេនដ៍ល័រ* ផ្តល់សក្ខីកម្ម ។ ហើយខ្ញុំក៏យល់ទៀតថាជាការសំខាន់ជាថា យើងគួរតែមានពេល១ថ្ងៃកន្លះសម្រាប់ឲ្យលោក *ដេវីដ ឆេនដ៍ល័រ* ជាសាក្សីដែលមានបំណង គោលបំណងច្បាស់លាស់នោះ ។ ហើយប្រហែលជាការប្រសើរជាងក្នុងការចាត់តាំងពេល២ថ្ងៃ រហូតដល់KW-08 និង 09 នោះ ពីព្រោះលោក *ដេវីដ ឆេនដ៍ល័រ* គឺជាអ្នកជំនាញឯករាជ្យ គាត់អត់មានទំនាក់ទំនងអ្វីជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញា ឬក៏ជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី ឬក៏ជាមួយមេធាវីការពារក្តីទេ ។ ហើយគាត់គឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្សចំនួនដែលមានចំណេះដឹងយ៉ាងជ្រាលជ្រៅបំផុតអំពីស-២១ ។

ដូច្នេះអ្វីដែលគាត់មានក្នុងការនិយាយនោះគឺនឹងមានទម្ងន់យ៉ាងច្រើន បើប្រៀបធៀបទៅនឹងសក្ខីកម្មរបស់ KW-08 និង 09 នោះ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវីដែលបានលើកឡើង ។ ហើយគួរឲ្យមានការចាប់អារម្មណ៍ច្រើនចំណុចដែលមានការពាក់ព័ន្ធ ជាពិសេសលើអ្នកជំនាញដែលកន្លងមកយើងមានបទពិសោធន៍ដែរថា យើងធ្វើសក្ខីកម្ម ស្តាប់សក្ខីកម្មអ្នកជំនាញគឺរយៈពេលតែងតែប្រើចំណាយពេលវេលាច្រើន នេះជាការពិត ។ ពីព្រោះដែលមានការយល់ដឹងទូលំទូលាយនៃអ្នកជំនាញនោះ គឺក្របខ័ណ្ឌគាត់គឺទូលំទូលាយណាស់ ។ ហើយយើងឃើញថាមានបញ្ហានេះមែន ។ ហើយអង្គជំនុំជម្រះកត់សម្គាល់បញ្ហានេះ ហើយយកទៅពិនិត្យពិចារណាពិភាក្សាគ្នាឲ្យបានល្អិតល្អន់ដើម្បីចៀសវាងថា តិចពេកឬក៏ច្រើនពេកដើម្បីឲ្យសមស្របថា ភាពដែលអាចទទួលបាននូវភាពយុត្តិធម៌ផង ហើយនិងឆាប់រហ័សផងនោះ ។

អញ្ជើញលោកមេធាវី ។

[១៥:១៥:១៣]

**លោក គង់ ពិសី៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំបាទសូមគោរពលោកចៅក្រមនិងលោកស្រីចៅក្រម ។

ខ្ញុំគិតថា ការលើកឡើងរបស់ខ្ញុំនេះគឺថា-- គឺវាតិចតួចស្ដួចស្ដើងទេ ប៉ុន្តែ បើសិនណាជាមានចំណាប់អារម្មណ៍ទៅអាចនឹងជួយជាប្រយោជន៍ដល់ការកាត់បន្ថយពេលវេលា ហើយសួរថាតើការសាកសួរដែលកំណត់ ដែលអង្គជំនុំជម្រះបានកំណត់គ្រប់គ្នា ថាតើបានដល់កម្រិតណា? ហើយចំណុចទី១ គឺថាបើសិនជាយើងគិតថា មួយថ្ងៃ ឬកន្លះថ្ងៃ បើយើងនិយាយពីថា ថ្ងៃ កន្លះថ្ងៃ មើលទៅដូចច្រើន កន្លះថ្ងៃដូចច្រើន មួយថ្ងៃក៏វាងច្រើន ។ តែបើយើងគិតពីម៉ោងវិញ យើងចាប់ផ្ដើមការងាររបស់យើងម៉ោងប្រាំបួនដល់ម៉ោងដប់ពីរ បានតែបីម៉ោងទេ ។ ហើយល្ងាចពីម៉ោងមួយកន្លះដល់ម៉ោងបួនកន្លះ បីម៉ោងដែរ ។ ដូច្នេះ មួយថ្ងៃបានប្រាំមួយម៉ោងទេ ហើយបើយើងគិតកន្លះថ្ងៃបានតែបីម៉ោងទេ ។ អ៊ីចឹងសួរថាតើយើងគិតដល់ពីការជំទាស់របស់ភាគីម្ខាងៗអត់? ជួនកាលនៅពេលដែលលើកសួរហ្នឹងមានការជំទាស់ហ្នឹងបញ្ហាទីមួយ ។ បញ្ហាទីពីរ ការជំទាស់ហើយមានសេចក្ដីសម្រេចពីអង្គជំនុំជម្រះ នេះត្រូវប្រើពេលវេលាទៀត ។ មួយទៀត បើយើងគិតពីពេលសម្រាកវិញ យើងសម្រាកម្ភៃនាទី បើយើងគិតថាកន្លះថ្ងៃ អ៊ីចឹង យើងចំណាយពេលបីម៉ោងតែយើងដកម្ភៃនាទីចេញ នៅសល់តែពីរម៉ោងសែសិបនាទីទេ នោះវាខ្លីវាខ្លីទៅៗ គឺនឹងខើចទៅ ។

ហើយមួយទៀតទាក់ទងទៅនឹងការបកប្រែ ជួនកាលមាការជំទាស់ផ្នែកខាងបកប្រែទៀតថា អ៊ឺ! ការបកប្រែនេះនិយាយដូចជាលឿនពេក អ៊ីចឹងសុំឲ្យយឺតបន្តិច ។ អានេះគឺជាបញ្ហាបន្តិច តែបន្តិចទេៗៗ អ៊ីចឹង អាបញ្ហាបន្តិចហ្នឹងធ្វើឲ្យការគិតរបស់យើងតែមួយថ្ងៃ កន្លះថ្ងៃហ្នឹងអាចទៅជា វាអាចទៅជាវែងអន្លាយទៀត មិនអាចគ្រប់គ្រងពេលវេលាបានទេ ។ អ៊ីចឹង ខ្ញុំសុំឲ្យអង្គជំនុំជម្រះនិងអង្គប្រជុំរបស់យើងពិចារណាពីពេលវេលាហ្នឹងផងថា តើបើយើងគិតថាកន្លះថ្ងៃសួរថា តើមានពេលប៉ុន្មាន? ហើយមួយថ្ងៃមានពេលប៉ុន្មាន? ខ្ញុំសូមលើកតែប៉ុណ្ណឹង ។ សូមអរគុណ ។

[១៥:១៧:២៧]

**ប្រធានអង្គជំនុំៈ**

អរគុណលោកមេធាវីដែលបានកត់សម្គាល់លើចំណុចអស់នេះ ។ ហើយចំណុចទាំងនេះ អង្គជំនុំជម្រះក៏បានធ្វើការកត់សម្គាល់ពិចារណាផងដែរ ដោយហេតុផលថាការជំទាស់ពីមុនៗមកដែលជាមានលក្ខណៈធំៗ ហើយអង្គជំនុំជម្រះត្រូវថយទៅពិចារណាដោយទាញនូវហេតុផលជាច្រើន ដូចជាការបង្ហាញឯកសារដែលច្រើនៗលើសលុប នោះទាមទារជាយុត្តិសាស្ត្រជាអន្តរជាតិដែលត្រូវយកមកពិនិត្យ

ដើម្បីបង្ហាញនិងជាសំអាងក្នុងការសម្រេចហេតុផលទាំងអស់នេះ ដែលនាំឲ្យមានការថយទៅពិចារណា ហើយប្រជុំច្រើនលើកច្រើនសា ហើយនិងចំណាយពេលវេលាយូរ ។

ដោយឡែកយើងកត់សម្គាល់ឃើញថា បន្ទាប់ពីយើងដោះស្រាយបញ្ហាចម្បងធំៗស្មុគស្មាញនោះមក អាបញ្ហាចុងក្រោយនេះ ដូចមិនមានការជំទាស់អីធំដុំទេ ដែលយើងអាចសម្រេចដោយដីកាសម្រេចដោយផ្ទាល់មាត់ភ្លាមៗបាន អាចចំណាយពេលតែប្រាំមីនុត ឬដប់មីនុតប៉ុណ្ណោះ ។ នេះជាការគណនាដែលយើងប៉ាន់ស្មានថាប្រហែលជាមិនមានបញ្ហាអីធំដុំដូចពេលដើមដំបូងនោះទេ ។

ទីពីរ គឺការគណនារបស់អង្គជំនុំជម្រះហ្នឹងយល់ឃើញដូច្នេះ ដោយសារយើងបានដាក់ពេលមួយថ្ងៃជាទូទៅ ហើយមួយថ្ងៃជាទូទៅនេះ ការគិតសាកល្បងរបស់អង្គជំនុំជម្រះគិតយល់ថា ប្រហែលជាសាក្សីមួយចំនួន យើងធ្វើសក្ខីកម្មមិនអាចមិនដល់មួយថ្ងៃទេៗ ។ អ៊ីចឹង ជាឱកាសមួយថា យើងនឹងអាចបន្តសម្រាប់សាក្សីបន្ទាប់ទៀត ពីព្រោះជាកន្លងមកយើងតែងតែធ្វើការ *វ៉េហ្សេវ* បានន័យថា សាក្សីទាំងអស់នោះ គាត់មកបន្តគ្នាដើម្បីរង់ចាំពេលឱកាសមានយើងគឺយើងអញ្ជើញគាត់ដើម្បីស្តាប់សក្ខីកម្មតែម្តង ។ អ៊ីចឹង បើយើងគណនាពីការដែលអាចថាមិនពេញមួយថ្ងៃ ហើយមានសាក្សីខ្លះអាចលើសពីមួយថ្ងៃហ្នឹងអាចបំពេញបង្គ្រប់គ្នាវិញបានសងគ្នាទូទាត់គ្នា បានយើងគណនាជាមធ្យមភាគគឺក្នុងសាក្សីម្នាក់មួយថ្ងៃនិយាយជាទូទៅ ។ អាហ្នឹង ជាទូទៅយើងគណនាដូចអ៊ីចឹង ។

[១៥:១៩:00]

ហើយបញ្ហាថា តើយើងធ្វើយ៉ាងម៉េច បើសិនជាពេលវេលាតែបីម៉ោងមួយពេល ហើយយើងត្រូវថយសម្រាកម្ភៃមីនុត ហើយនិងអាចជំទាស់អីប្រាំមីនុត-ដប់មីនុតអីទៀតនោះថាយើងធ្វើម៉េច? បញ្ហានេះអង្គជំនុំជម្រះនឹងប្រឹងប្រែងហើយនិងគណនាឲ្យបានកម្រិតអតិបរមា បានន័យថាការសម្រិតសម្រាំងនូវសំណួរដែលសួរចំពោះសាក្សីរូបនោះក៏អង្គជំនុំជម្រះខ្លួនឯងក៏ត្រូវសម្រិតសម្រាំងនៅក្នុងសំណួរជាក់លាក់មួយចំនួនដើម្បីឲ្យការសួរហ្នឹងចំបញ្ហាដែរ មិនវែងទេ គឺទាមទារថាកាត់បន្ថយនូវទាំងចំនួន ទាំងរបៀបក្នុងការសួរហ្នឹងដើម្បីឲ្យប្រកបដោយបច្ចេកទេសដែលអាចទទួលយកបាន។ ហើយដើម្បីទុកពេលវេលាសមស្របឲ្យភាគីចូលរួមនៅក្នុងការតាំងសំណួរនោះដែរ ។ នេះការគិតមើល យើងមើលឯកសារផ្ទៀតផ្ទាត់ទៅប្រហែលជាយើងអាចដំណើរការដូច្នេះ ។

ហើយឆ្លងកាត់ពិសោធន៍ដែលយើងបានកំហិតនេះ យើងឃើញថា នៅក្នុងអំឡុងពេលសវនាការនៅក្នុងសប្តាហ៍នេះ យើងបានគ្រោងធ្វើគឺពីរសប្តាហ៍កន្លះយើងប្រកាសហើយ អ្ហូ! ពីរថ្ងៃកន្លះ ប៉ុន្តែដោយ

សារយើងបច្ចេកទេសក្នុងការរៀបចំចុងក្រោយនេះ យើងធ្វើតែមួយថ្ងៃមួយព្រឹកទេ អ្វីដែលយើងគ្រោងមួយថ្ងៃកន្លះ យើងគ្រោងយើងគណនាពេលវេលាខុសដល់ពាក់កណ្តាល ។ វាផ្ទុយពីលើកមុន ពីមុនលើកមុន យើងថា ធ្វើសវនាការតែពីរថ្ងៃឬអីអ៊ីចឹងទេ ស្រាប់តែដល់ធ្វើសវនាការបែរជាបួនថ្ងៃឬប្រាំថ្ងៃ ។ នេះគឺជាបទពិសោធន៍ដែលយើងបានជួបប្រទះ ហើយយើងបានគណនាចុះឡើងទៅឃើញថាមានបទពិសោធន៍ចុងក្រោយនេះកាន់តែមានលក្ខណៈសុក្រិត្យជាងអ្វីដែលយើងបានធ្វើ ។ អ៊ីចឹងយើងសង្ឃឹមថា អ្វីដែលការគណនារបស់អង្គជំនុំជម្រះហ្នឹងគឺប្រហែលជាអាចដោះស្រាយបញ្ហាបាន ។

ប៉ុន្តែ ទោះបីយ៉ាងណា អរគុណណាស់ក្នុងការកត់សម្គាល់របស់មេធាវីនេះ គឺថាវា ស្របគ្នានឹងការគិតការជជែករបស់មតិមួយចំនួនរបស់ចៅក្រមក្នុងអង្គជំនុំជម្រះដែរ ដែលមានការចាប់អារម្មណ៍ដែលកើតមានឡើងយថាហេតុនេះ ។

សូមអញ្ជើញលោកមេធាវី ។ សហព្រះរាជអាជ្ញា ។

[១៥:២១:២៧]

**លោក វាលៀម ស្មីត៖**

សូមអរគុណលោកប្រធាន ។ខ្ញុំគិតថា វាមានបញ្ហាមួយទៀតទាក់ទងទៅនឹងតម្លៃនៃចម្លើយដែលយើងដាក់នៅក្នុងតាមវិធាន៨៧ ទាក់ទងទៅនឹងតម្លៃនៃសក្ខីកម្ម ។ ខ្ញុំសូមលើកឡើងថា មេធាវីការពារក្តីបានលើកឡើងថា ពួកគេនៅតែជំទាស់ទៅលើចម្លើយសារភាពមួយចំនួន ប្រសិនបើដាក់តាមវិធាន៨៧ ។ អ្វីដែលខ្ញុំសូមលើកឡើងនោះ ប្រសិនបើមេធាវីការពារក្តីធ្វើការជំទាស់ខ្លាំងទៅលើវិធាន៨៧ ចំពោះការដាក់ឯកសារនោះ យើងគួរតែកោះហៅសាក្សីនោះចូលមកក្នុងសវនាការហើយធ្វើការតទល់ បើមិនដូច្នោះទេ ប្រសិនបើយើងមិនតទល់ទៅលើបញ្ហាសំខាន់នោះទេ គឺវាមិនអាចដោះស្រាយទៅលើអង្គហេតុនិងការចោទប្រកាន់នោះទេ ។

ខ្ញុំមិនលើកឡើងអំពីបញ្ហាតូចៗនោះទេ ដែលលោកលោកស្រីចៅក្រមអាចពិចារណានិងទាក់ទងទៅនឹងថាតើភស្តុតាងនោះវាស៊ីគ្នាដែរឬទេ? ហើយវាស៊ីទៅនឹងសក្ខីកម្មរបស់សាក្សីផ្សេងទៀតដែរ ឬទេ? ហើយលោកលោកស្រីចៅក្រមអាចធ្វើការដាក់ទម្ងន់ទៅលើសក្ខីកម្ម ។ ប៉ុន្តែចំពោះការចោទប្រកាន់ធ្ងន់ៗផ្សេងៗនោះ គឺយើងគួរតែកោះហៅសាក្សីហ្នឹង ហើយក្នុងករណីដែលមានការជំទាស់ខ្លាំងក្លាពីជនជាប់ចោទ ។

ហើយចំពោះការកោះហៅសាក្សីនោះគឺដើម្បីឲ្យសាធារណជនគាត់បានស្តាប់សក្ខីកម្មផង ដែលវាទាក់ទងទៅនឹងការស្វែងរកការពិត ។ ហើយប្រសិនបើខ្ញុំលើកឡើងអំពីសាក្សីមួយ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីមួយនោះនៅក្នុងសវនាការអសាធារណៈគឺ អ៊ុក ប៊ុនសេង គាត់និយាយថា បន្ទាប់ពីបែកភ្នំពេញពីរបីថ្ងៃក្រោយមកគឺ ឌុច នៅភ្នំពេញ ហើយគាត់មានកូនចៅនៅជាមួយគាត់ គាត់បង្គាប់កូនចៅរបស់គាត់ឲ្យធ្វើការ ធ្វើទារុណកម្មនិងសម្លាប់ ។ នេះគឺជាពីរបីថ្ងៃក្រោយពីវៀតណាម គាត់ចូលមកកម្ពុជា នេះគឺជាការចោទប្រកាន់មួយ។ ដូច្នេះ ហើយវាជាចំណុចមួយដែលសំខាន់ថា ហេតុអ្វីបានជាមានការចោទប្រកាន់ដូច្នេះ ហើយយើងត្រូវរកការពិត ។

ហើយប្រសិនបើមេធាវីជំទាស់នោះ គឺយើងនឹងត្រូវតែកោះហៅសាក្សីមកតទល់ ។ ហើយចំពោះភស្តុតាងដែលវាឋិតនៅក្នុងចំណុចដែលធ្ងន់ធ្ងរ ហើយនិងអង្គហេតុផ្សេងៗដែលមានការជំទាស់នោះ យើងគួរតែកោះហៅសាក្សី ។ ហើយដូចជាជនជាប់ចោទ គាត់បានលើកឡើងថាគាត់មានការភ័យខ្លាចហើយអស់សង្ឃឹមចំពោះរបបហ្នឹង គឺវាហាក់ដូចជាផ្ទុយទៅនឹងភស្តុតាងដែលខ្ញុំលើកឡើង ។ ដូច្នេះ ហើយមេធាវីហាក់ដូចជាជំទាស់ ដូច្នេះ យើងគួរតែកោះហៅសាក្សី ។ យើងគួរតែមានការតតាំងរយៈពេលម្តែនាទីឬក៏សាមសិបនាទី ហើយវាខុសគ្នានៅពេលដែលយើងបង្ហាញការពិតក្នុងអង្គហេតុទូទៅ ហើយយើងអាចបញ្ជាក់ឲ្យសាធារណជន គាត់បាដឹងអំពីករណីទាំងអស់នេះផងដែរ ។ សូមអរគុណ ។

[១៥:២៤:៤៦]

**ប្រធានអង្គជំនុំ៖**

អរគុណលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិដែលបានលើកឡើងអំពីចំណុចនេះ ហើយចំណុចសុទ្ធតែជាចំណុចសំខាន់ ហើយយើងបានលើកឡើងច្រើនហើយ អាចមានលក្ខណៈ ទីមួយអាចយើងៗតាមការយល់ឃើញរបស់ខ្ញុំផ្ទាល់វាអាចមានបញ្ហាខុសគ្នាប្រហែលជាខាងទស្សនៈ ។ ជួនកាលការអានផង អាននឹង វារបៀបអានហ្នឹងវាសព្វគ្រប់ ឬក៏មិនសព្វគ្រប់ ។ អានេះជាបញ្ហាមួយ ។ បញ្ហាទីពីរ ជួនកាលអានហើយ វាមានការយល់ខុសគ្នារវាងភាគីទាំងពីរ ។ ខាងភាគីដាក់បន្ទុកអាចយល់ផ្សេង ហើយភាគីដោះបន្ទុកអាចយល់ផ្សេង ។ តម្លៃនៃភស្តុតាងតែមួយអាចយល់ខុសគ្នាអំពីសារប្រយោជន៍របស់វាថា មានតម្លៃដាក់បន្ទុក ឬក៏មានតម្លៃដោះបន្ទុក ធ្ងន់កម្រិតណា អីកម្រិតណាអាចៗមានបញ្ហា ។

អ៊ីចឹង បញ្ហាដែលថា គួរដោះហ្នឹងតាមការយល់ដឹងរបស់ខ្ញុំវាគួរតែដោះស្រាយយ៉ាងម៉េច ពីព្រោះថាឥឡូវ ឧទាហរណ៍ថា អង្គជំនុំជម្រះសម្រេចហើយ ហើយមិនបានកោះហៅសាក្សីរូបណាមួយមក

សក្ខីកម្មទេ ។ ស្រាប់តែដល់ពេលយើងអាននូវឯកសារឡើង មានការជំទាស់ពីខាងភាគីមេធាវីការពារក្តី ឬក៏ជនជាប់ចោទលើសក្ខីកម្មរបស់សាក្សីដែលយើងអាននោះ ។ បានន័យថា យើងមិនអាចតទៅមុខទៀតបានទេ ពីព្រោះអត់មានសាក្សីដែលសក្ខីកម្មមានការជំទាស់តវ៉ានេះ ត្រូវអញ្ជើញយកមកជជែក ឬក៏យ៉ាងម៉េច? ឬក៏យើងពិនិត្យផ្ទៀងផ្ទាត់ទាំងអស់គ្នាថា ការស្នើឡើងរបស់អង្គជំនុំជម្រះហ្នឹងវាមានការព្រមព្រៀងយ៉ាងម៉េចរបស់ភាគីជាមួយនឹងខាងមេធាវីការពារអីអ៊ីចឹងថា មើលឯកសារហ្នឹងគឺនឹងសង្ឃឹមថាមិនមានការជំទាស់ទេ ឬក៏ព្យាករណ៍ថា មានជំទាស់ដែលត្រូវតែអាចកត់សម្គាល់អង្គជំនុំជម្រះនឹងពិចារណាដើម្បីធ្វើការកោះហៅ ។ គ្រាន់តែកំហិតនៃការកោះហៅដោយរបៀបនេះ គឺយើងអាចថា ការពន្លាតហ្នឹងយើងអាចជជែកដេញដោលតែកម្រិតនៃចំណុចដែលវាត្រូវតែតទល់គ្នាបានហើយ ចំណុចផ្សេងទៀតដែលមិនមានបញ្ហាយើងអាចអាន ។ អ៊ីចឹងបានទេដើម្បីឲ្យផ្នែកពេលវេលា វាអាចលឿន បានន័យថា បើសិនជាយើងតទល់តែក្នុងអំឡុងពេលវេលាកន្លះម៉ោង ហើយបណ្តាញផ្សេងទៀតអត់មានការជំទាស់ទេ យើងយកឯកសារហ្នឹងអានជាមូលដ្ឋានបញ្ចប់បញ្ហាក៏ដូចជាអាចលឿនដែរ ។ នេះជាមធ្យោបាយជាការយល់ដឹងរបស់ខ្ញុំ ដើម្បីពន្លឿននៃកិច្ចដេញដោលរបស់យើង ។ នេះគឺជាមធ្យោបាយ តើយើងអាចដោះស្រាយរបៀបអ៊ីចឹងបានដែរទេ? បើសិនជាយើងអត់ដឹងទាំងអស់គ្នាជួនកាល វាមើលអត់សព្វគ្រប់ទៅវាអត់អាចដឹងទេ ។ ដល់ពេលដេញដោលមួយៗបានយើងយកមក វាអាចដឹងហើយវាអាចខកពេលដែរ ព្រោះអំឡុងពេលនៃការកោះហៅត្រូវទាមទារយ៉ាងហោចពីរសប្តាហ៍ដែរ ដើម្បីហៅគេ ដើម្បីគោរពនូវគោលការណ៍នៃការគំលាតគ្នារវាងការកោះហៅជាមួយនឹង-- គេដឹងខ្លួនដើម្បីឲ្យគេត្រៀមខ្លួនចូលមកសវនាការនោះ ។ បើមិនអ៊ីចឹងទេ នីតិវិធីវាអាចមោឃៈនៅក្នុងដំណើរការនៃការកោះហៅសាក្សីចូលសវនាការតាមនីតិវិធី ។

[១៥:២៧:៤៩]

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោក លោកស្រីចៅក្រមជាទីគោរព! អ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើង គឺវាហាក់ដូចជាចូលទៅដល់ចំណុចទីមួយដែលលោកបានលើកឡើងថា យើងគួរតែមើលចំណុចគ្រប់បែបយ៉ាងឡើងវិញ ។ ហើយយើងនឹងចំណាយពេលដប់ឆ្នាំឯណោះ ប្រសិនបើយើងធ្វើដូច្នេះ នៅក្នុងការជំនុំជម្រះលើរឿងក្តីឌុចនោះ គឺវាដំណើរការនេះអាចចំណាយពេលដប់ឆ្នាំ ។ ឬក៏យើងអាចសម្រេចទៅតាមអ្វីដែលបានប្រមូលរួចហើយនេះ យើងមានឯកសារច្រើនណាស់ ។

លោកសហព្រះរាជអាជ្ញាមកពីប្រព័ន្ធដែលមានការសារភាពទោស ការចរចាទោស ។ លោកដឹងច្បាស់ណាស់នៅពេលដែលបុគ្គលគាត់សារភាពទោស ។ អង្គហេតុមួយចំនួនគឺគេទុកចោលដោយសារតែការសារភាពទោសរួចហើយនោះ ។ ដូច្នេះហើយខ្ញុំសូមកុំឲ្យយើងចូលទៅដល់ចំណុចដែលយើងពិភាក្សាទីមួយ ។ អង្គសវនាការបានសម្រេចយ៉ាងមានលក្ខណៈវៃឆ្លាតទៅលើចំណុចនេះ ។ ហើយវាហាក់ដូចជា វាមានភាពជាន់គ្នាទៅលើសាក្សីដែលមានរួចហើយនៅក្នុងបញ្ជី ដើម្បីថាយើងមិនចង់កោះហៅទៅលើសាក្សីទាំងអស់នេះ ។ ដូច្នេះ ខ្ញុំសូមលើកឡើងថា គឺថាកុំមានការភ័យខ្លាចអីគឺជនជាប់នោះគឺគាត់សារភាពទោសទៅហើយ ។

**លោក វាលៀម ស្មីត៖**

វាមិនមែនជាបញ្ហានៃការសារភាពទោសនោះទេ ហើយយើងមិនអនុវត្តចំណុចនេះនៅក្នុងនេះទេ ។ យើងនិយាយអំពីគោលការណ៍ហួសពីមតិសង្ស័យហើយយើងត្រូវដោះស្រាយថា តើជនជាប់ចោទគាត់មានឆន្ទៈប៉ុន្មានក្នុងការចូលរួមក្នុងបទឧក្រិដ្ឋកម្ម? នេះគឺជាចំណុចដែលខ្ញុំលើកឡើងថា វាជាចំណុចសំខាន់ ហើយវាជាចំណុចពិស្ដារនិងចម្បងនៅក្នុងរឿងក្ដី ។ ថាតើគាត់ចូលរួមដោយមានចេតនានិងយល់ព្រមដោយស្ម័គ្រចិត្តដែរ ឬទេនៅក្នុងព្រឹត្តកម្មទាំងអស់នោះ?

[១៥:៣០:២៦]

**ប្រធានអង្គជំនុំ៖**

អរគុណហើយការចាប់អារម្មណ៍នេះ ។ ខ្ញុំនៅតែចាំថា កាលប្រជុំលើកមុនយើងបានពិភាក្សាពីបញ្ហានេះរួចហើយដែររវាងការដែលបង្កើប ឬផ្ដួចផ្ដើមគំនិតនៅក្នុងការកាត់បន្ថយនៃចំនួនសាក្សីប្រហែលជាលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិជាអ្នកមានមតិមួយក្នុងចំណោមអ្នកគាំទ្រក្នុងការលើកឡើងក្នុងការពន្លឿននៃនីតិវិធីក្នុងការកាត់បន្ថយសាក្សីនេះ ។

ហើយបញ្ហាទីពីរ គឺអាចមានបញ្ហាផ្ទុយគ្នារវាងការកាត់បន្ថយសាក្សី ហើយនិងការពន្លឿននីតិវិធី ហើយនិងការបង្ហាញភស្តុតាងឲ្យលើសពីមតិសង្ស័យ ។ នេះយើងបានជជែកគ្នារួចហើយ វាអាចមាន--គំនិតពីរហ្នឹង វាអាចខុសគ្នា ប្រសិនជាយើងគោលការណ៍ថា ដាច់ខាតត្រូវតែប្រឹងប្រែងក្នុងការបង្ហាញភស្តុតាងដាក់បន្ទុកឲ្យលើសពីមតិសង្ស័យនោះ វាទាមទារឲ្យការជជែកហ្នឹងច្រើនហួតចត់ ច្រើនជាអតិបរមា បើយើងនិយាយពីប្រើភាសាវិញ ។ បើពាក្យអតិបរមាទាំងអំឡុងពេលធ្វើសវនាការចំពោះសាក្សី

នីមួយៗ ចំពោះជនជាប់ចោទ ចំពោះភាគីដែលចូលរួមក៏ដូចជាចំនួនដែលត្រូវចូលរួមដាច់ខាតត្រូវតែចូលរួមទាំងអស់ ។

[១៥:៣១:៤១]

អ៊ីចឹងបានយើងរកវិធីមួយថា ធ្វើយ៉ាងណាឲ្យការដែលដំណើរការសវនាការរឿងក្ដីនេះប្រព្រឹត្តទៅប្រកបដោយយុត្តិធម៌ ហើយឲ្យឆាប់រហ័សផង ។ អ៊ីចឹង ហើយបានជាយើងមានការជជែកវែកញែកគ្នាលើចំណុចនេះដើម្បីកាត់បន្ថយ ហើយក៏ជាការស្ដាប់នូវភាគីដែលចូលរួមមតិយោបល់កាលពីប្រជុំថ្ងៃទី១១ ខែ៦ ដែរ ដែលជាមូលដ្ឋានក្នុងការកាត់បន្ថយនេះ ។ គ្រាន់តែការពិភាក្សានេះថា តើវាមានលក្ខណៈសំខាន់យ៉ាងណាខ្លះ ឬក៏វាកម្រិតដែលអាចគួរតែមិនចាំបាច់ដែលយកមកធ្វើបានដើម្បីយើងមានមូលដ្ឋានក្នុងការសម្រេចចុងក្រោយ ។ អានេះឲ្យវាមានការពិភាក្សា ហើយឲ្យវាការសុក្រឹត្យនៅក្នុងការដំណើរការសវនាការទៅមុខកុំឲ្យវាការឃ្លាតឆ្ងាយពេក ឬក៏មានការប៉ះពាល់ទៅដល់ភាពយុត្តិធម៌ដោយមូលហេតុនៃការដែលប្រឹងកាត់ពេកឲ្យខ្លីពេកទៅ វាប៉ះពាល់លើយុត្តិធម៌ ។ នេះប្រកបដោយភាពយុត្តិធម៌អាចប៉ះពាល់ តែប្រសិនបើជាយើងបណ្ដោយថា ប្រឹងឲ្យរកយុត្តិធម៌វារំលោភនូវគោលការណ៍នៃការឆាប់រហ័សក៏វាមិនល្អដែរ អាហ្នឹងយើងបានឯកភាពគ្នារួចហើយ ។ អ៊ីចឹង មធ្យោបាយដែលយើងប្រើនេះប្រហែលជាខ្ញុំគិតថាគំនិតខុសគ្នាតិចតួចទេ ដូចជាឯកភាពគ្នាជាទូទៅហើយនូវគោលការណ៍ទាំងអស់នេះ។ ពេលខ្លះ គឺយើងមានការខុសគ្នាតិចតួចលើការតម្រូវការនៃការស្ដាប់ ឬក៏មិនស្ដាប់សាក្សីដែលបានស្នើឡើងដោយអង្គជំនុំជម្រះ ។

[១៥:៣៣:០៨]

ហើយបញ្ហាទីពីរ គឺមួយទៀតហ្នុងគឺខុសគ្នារវាងពេលទេ រវាងពេលទេដោយសារមានចំណុចជាច្រើនដែលថាទាមទារឲ្យមានការបង្កើនឡើងនូវពេលវេលា ប៉ុន្តែ ការបង្កើនឡើងនេះ ខ្ញុំមើលទៅដូចជាមិនមានការបង្កើនឡើងច្រើនទេ ភាគច្រើនគឺដែលសូមបង្កើនតែកន្លះថ្ងៃទេៗ ដែលជាពិសេសចំពោះមនុស្សពិសេសៗសំខាន់ដូចជាអ្នកជំនាញជាដើម ។ ហើយក៏មានការគិតគូរថា សាក្សីខ្លះក៏គួរតែត្រូវកាត់បន្ថយអំឡុងពេលខ្លះ អាហ្នឹងចាំអង្គជំនុំជម្រះពិចារណាបន្ថែមទៀតថាគួរប្រឹងប្រែងយ៉ាងម៉េចដើម្បីអាចធ្វើទៅបាន ។

ហើយក៏ជាការអរគុណដែលថា សុទ្ធតែការរួមមតិយោបល់នោះសុទ្ធតែល្អៗ ដែលអង្គជំនុំជម្រះនឹងប្រឹងប្រែងយកមតិយោបល់អស់លោក លោកស្រី យកទៅពិចារណាដើម្បីសម្រេចរឿងនេះឲ្យបានត្រឹមត្រូវឲ្យបានល្អដែលអាចទទួលយកបាន ។

ហើយក៏ជាចំណុចទីបួននៃរបៀបវារៈរបស់យើងគឺការដែលស្តាប់សក្ខីកម្មចំពោះសាក្សីមួយចំនួនតាមរយៈការចូលរួមពីចម្ងាយ ។ ហ្នឹងគឺវីដេអូ *ខនហ្វឺរិន* ដែលយើង-- នេះគឺមានសាក្សីចំនួនបីរូប មិញគឺលោក ហ្វ្រង់ស្វ័រ រូ បានលើកឡើងហើយថាសាក្សី *ហ្វ្រង់ស្វ័រ ស៊ីរ៉ូនី វាលបូ* នេះគឺលោកបានសុំថាឲ្យធ្វើចំពោះមុខ ។ នេះតាមខ្ញុំស្តាប់ដែលគាត់បានលើកឡើងអម្បាញ់មិញ ដោយសារគាត់ភ្ជាប់ទេ ។ ឥឡូវខ្ញុំគ្រាន់តែជូនទៅវិភាគគូភាគីដើម្បីពិភាក្សាអំពីរបៀបវារៈទីបួនថា តើអស់លោក លោកស្រី មានមតិយោបល់យ៉ាងម៉េចដែរអំពីការដែលធ្វើការស្តាប់សក្ខីកម្មគាត់ពីចម្ងាយនេះ ។ ហើយបើមានសូមអញ្ជើញដូចៗតំណាងសហព្រះរាជអាជ្ញា ។

**លោក វីលៀម ស្មីត៖**

លោក លោកស្រីចៅក្រម យើងយល់ស្របវាមានប្រសិទ្ធភាពណាស់ ហើយយើងហាក់ដូចជាមិនបាត់អីច្រើន ។ យើងដូចជាមិនបាត់អីច្រើនទៅលើសាក្សីទាំងអស់នេះទេ ។

**ប្រធានអង្គជំនុំ៖**

តំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយលើរបៀបវារៈទីបួន មានមតិយោបល់អ្វីទេ?

**លោក អាឡាំង វែនណឺ៖**

យើងអត់មានមតិយោបល់ទៅលើចំណុចទីបួនទេ ប៉ុន្តែ ខ្ញុំសូមលើកយោបល់បន្ថែមដោយខ្លី ។ យើងឃើញមានអ្នកជំនាញមួយដែលយើងបានស្នើ ហើយលោកសម្រេចថានឹងកោះហៅគឺ *ឆាលឌីស្លី* ដែលស្ថិតនៅ *ឆាលស្ទីកលី* ដែលលោក លោកស្រីនឹងពិចារណា ។

ខ្ញុំយល់ថាអ្នកជំនាញមួយនេះ គាត់មានបញ្ហាចំពោះពេលវេលានិងថវិកាផ្សេងៗទាក់ទងទៅនឹងការស្នើសុំរបស់គាត់ គឺប្រាក់ឧបត្ថម្ភ ។ ដោយសារគាត់ជាសាក្សីនិងអ្នកជំនាញកោះហៅដោយតុលាការ ខ្ញុំប្រាប់គាត់ឲ្យធ្វើការទាក់ទងជាមួយនឹងអង្គសវនាការដោយផ្ទាល់តែម្តង ហើយយើងអត់ដឹងថា គាត់ទាក់ទងនោះទេ ។

ដូច្នេះហើយយើងវាជាភាពសមរម្យដែលយើងជម្រាបជូនអង្គសវនាការថា វាអាចជាបញ្ហាចំពោះអ្នកជំនាញនេះ ។ ខ្ញុំអត់ដឹងថាគាត់ទាក់ទងជាមួយនឹងលោកដែរឬទេ? ឬក៏ខាងបុគ្គលិករបស់លោកអង្គ

ចៅក្រមធ្វើការទាក់ទងស្រាវជ្រាវទៅលើបញ្ហានេះ ។ ហើយខ្ញុំគិតថា ខ្ញុំនឹងចង់មានការបំភ្លឺបន្ថែមទៀតនៅពេលក្រោយ ប្រសិនបើខ្ញុំមាន ។

[១៥:៣៧:៣១]

**ប្រធានអង្គជំនុំ៖**

ឆ្លើយតបនឹងការលើកឡើងរបស់មេធាវី អាឡាំង វ៉ែនណឺ អម្បាញ់មិញនេះគឺបានទទួល ខ្ញុំបានទទួលព័ត៌មានពីក្រឡាបញ្ជីសាលាដំបូងគឺបានបញ្ជាក់ថា គាត់អត់អាចអញ្ជើញមកផ្តល់សក្ខីកម្មនៅអង្គជំនុំជម្រះរបស់យើងបានទេ ។

**លោក អាឡាំង វ៉ែនណឺ៖**

ខ្ញុំសូមអរគុណចំពោះការជម្រាបព័ត៌មាននេះជូនខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញក្រុមពីរ ក្រុមពីរពាក់ព័ន្ធជាមួយនឹងរបៀបវារៈទីបួនបាទ ។

**លោក គង់ ពិសី៖**

សូមអរគុណលោកប្រធាន ។ សូមគោរពលោកចៅក្រមនិងលោកប្រធាននិងលោកស្រីចៅក្រមម្តងទៀត ទាក់ទងបញ្ហានេះគឺថាខ្ញុំក៏ ក្រុមខ្ញុំក៏សូមឯកភាពដែរ ក៏ប៉ុន្តែនៅ ហើយចំណុចសំខាន់ដែលមិនមែនបច្ចេកទេសរបស់យើងគឺជាបច្ចេកទេសរបស់ដែលគេហៅថា *អាយធី* ។ ពីព្រោះខ្ញុំឃើញ ខ្ញុំដឹងតែពីការជឿលឿនហើយខាង*អាយធី* ប៉ុន្តែ នៅពេលដែលផ្តល់សក្ខីកម្មហ្នឹង ថាតើកិច្ចការតភ្ជាប់មកខាងមកពីចម្ងាយមកយើងវាលឿនប៉ុន្មាន ឬមួយក៏អាក់ខានប៉ុន្មាន ។ កាលណា វាមានការអាក់ខានទៅហ្នឹងគឺថា យើងខាតពេលវេលា ។ អ៊ីចឹងបើសិនជាមានអាយធីនៅទីនេះគាត់អាចផ្តល់ព័ត៌មានហ្នឹងដល់អង្គជំនុំជម្រះផងបានទេបាទ? ពីការទាក់ទងពីចម្ងាយហ្នឹង ពីព្រោះយើងកន្លងមកគ្រាន់តែយើងតភ្ជាប់តែក្នុងនេះ គឺថាមានការលំបាកខ្លះ ខ្ញុំជឿថាគាត់មានជំនាញ ប៉ុន្តែ នៅមានការលំបាកខ្លះនាំឲ្យមានការចំណាយពេល ។ ចុះទម្រាំតែពីបរទេសមកយើងនេះទៀត តើគាត់មានការជឿនលឿនប៉ុន្មាន? ហ្នឹងសូមអរគុណ ។

[១៥:៣៩:១៩]

**ប្រធានអង្គជំនុំ៖**

អរគុណនូវការកត់សម្គាល់របស់មេធាវីនេះ ហើយប្រហែលជាដូចខ្ញុំដែរ ។ ពីព្រោះខ្ញុំក៏ជាបុគ្គលមួយ ឬក៏ជាមនុស្សម្នាក់នៃកម្ពុជាដែលក៏មានបញ្ហាប្លែកសម្រាប់ខ្ញុំដែរ ប៉ុន្តែ ដោយសារការដែលសួរនាំពិភាក្សាទៅ គឺថាអះអាងផ្នែកខាងបច្ចេកទេសព័ត៌មានវិទ្យានៅទីនេះគឺគេបានសម្តែងថាកុំឱ្យយើងមានការព្រួយបារម្ភអំពីបញ្ហានោះអី ។ អ៊ីចឹងបានន័យថា អង្គជំនុំជម្រះមុននឹងដាក់បញ្ហានេះហើយទទួលយកពិភាក្សាហ្នឹង គឺបានធ្វើការពិគ្រោះយោបល់ជាមួយនឹងអ្នកជំនាញ ហើយខាងអាយធីនៅទីនេះរួចហើយ ។

ហើយនោះជាកង្វល់លោកគឺកង្វល់ខ្ញុំមុនគេ ព្រោះខ្ញុំមិនដឹងថា តើរបៀបធ្វើយ៉ាងម៉េច ហើយធ្វើបានដែរអត់នោះ? មុននឹងពិភាក្សានេះគឺមានការឆ្លើយតប បានន័យថា ការអះអាងគេអាចធ្វើបាន ។ ហើយយើងនឹងគណនាទៀតម្តងទៀត ថាតើយើងធ្វើពេលណាដែលសមស្របរវាងពេលវេលាយប់ថ្ងៃដែលមានលក្ខណៈខុសគ្នារវាងខាងឯនាយសមុទ្ទ ហើយជាមួយនិងយើងនោះគឺក៏គេបានគណនាហើយជាក់លាក់គេនឹងប្រាប់យើងនៅពេលក្រោយ ។ តែអំឡុងពេលនេះ ទោះបីព្រឹក ឬល្ងាចយើងមានឱកាសសម្រាប់តែធ្វើការងារហ្នឹងបាន ។ ម៉េចជាការត្រឹមត្រូវទេ ការកត់សម្គាល់របស់ខ្ញុំនេះ លោកស្រីចៅក្រមពីបច្ចេកទេសដែលយើងបានធ្វើការជាមួយនឹងផ្នែក *អាយធី* អំពីការធ្វើវីដេអូ *ខនហ្វឺរិន* នេះ?

**លោកស្រី ស៊ីលវីយ៉ា ហ្វីនស្គី៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមានចំណុចមួយទាក់ទងទៅនឹង វីដេអូ *ខនហ្វឺរិនស៊ីង* ហ្នឹងគឺវាអត់ទាក់ទងទៅនឹងសាក្សីទេ ប៉ុន្តែទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី។ តើលោកប្រធានអាចបញ្ជាក់ឱ្យខ្ញុំបានដឹងច្បាស់ទេថា តើភាគីដើមបណ្តឹងរដ្ឋប្បវេណីគឺ E2/77 ដែលជាកូនក្តីរបស់យើងខ្ញុំនឹងគាត់ហ្នឹងឈឺ ហើយគាត់មិនអាចមកតុលាការបានទេ ហើយខ្ញុំមិនដឹងថាតើស្ថានភាពនុ៎ងវាយ៉ាងដូចម្តេចទេក្នុងរយៈពេលប៉ុន្មានសប្តាហ៍ ឬក៏ខែទៅមុននេះ ។ អ៊ីចឹង ក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណីដែលរស់នៅក្នុងភូមិនៅឆ្ងាយ ថាតើ វីដេអូ *ខនហ្វឺរិន* ហ្នឹងអាចធ្វើបានទេ ខ្ញុំគ្រាន់តែចង់សួរបញ្ជាក់តែប៉ុណ្ណោះខ្ញុំមិនចង់បានចម្លើយនៅពេលនេះទេ គ្រាន់តែដើម្បីឱ្យលោក លោកស្រីចៅក្រមយកទៅពិចារណាតែប៉ុណ្ណោះ ។ សូមអរគុណ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំគិតថា លទ្ធភាពក្នុងការមានវីដេអូ *ខនហ្វឺរិន* នៅឯតាមតំបន់ជនបទនោះគឺមិនមែនជាការងាយស្រួលទេ ។ ដូច្នេះ ខ្ញុំគិតថា យើងត្រូវចាំអំពីចំណុចនេះផងដែរ ។ យើងខ្ញុំពេញចិត្តណាស់ដែលបានឮថាមានដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន បានទទួលថាពួកគាត់ហ្នឹងចាស់ហើយ ហើយមានការលំបាកក្នុង

ការធ្វើដំណើរផងដែរ ។ ក៏ប៉ុន្តែ យើងត្រូវពិចារណាផងដែរថា ប្រទេសកម្ពុជាមិនមានបណ្ដាញទូលំទូលាយក្នុងការប្រាស្រ័យទាក់ទងដូចនៅប្រទេសមួយចំនួនទៀតនោះទេ ។ ហើយយើងត្រូវចាំអំពីចំណុចនេះផងដែរ ។ អ៊ីចឹងដូច្នេះយើងមិនអាចធ្វើការសន្យាបានទេ ។

[១៥:៤៣:២៤]

**ប្រធានអង្គជំនុំ៖**

ជាតទៀតមេធាវីក្រុមបី ។

**លោក គឹម ម៉េងឃី៖**

សូមអរគុណលោកប្រធាន ។ ក្រុមយើងខ្ញុំមិនមានការជំទាស់ទៅនឹងការធ្វើស្ដាប់សក្ខីកម្មតាមវីដេអូ *ខនហ្វឺរិន* ទេ ។ ហើយក្រុមយើងខ្ញុំក៏មានការកត់សម្គាល់ដែរ ពាក់ព័ន្ធទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណីរបស់ក្រុមយើងខ្ញុំគឺមានការស្ដាប់តាមវីដេអូ ខនហ្វឺរិន ដែរ ។ អ៊ីចឹងក៏យើងខ្ញុំអាចសុំឲ្យអង្គជំនុំជម្រះបញ្ជាក់អំពីលទ្ធភាពថាតើអាចធ្វើទៅបាន ឬមិនបានតាមវិធីវីដេអូ *ខនហ្វឺរិន* ហ្នឹងកម្រិតណាមួយដែលពួកយើងអាចជម្រាបដើមបណ្ដឹងរបស់យើងអំពីលទ្ធភាពនៃការស្ដាប់ចម្លើយរបស់ដើមបណ្ដឹងតាមវីដេអូ *ខនហ្វឺរិន* ហ្នឹងបាទ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណ ។ ហើយកុំអាល់ងើបអីលោក ហុង គឹមសួន ។ ផឹកទឹកសិន ។ ដោយសារ ឌីវីឌី អស់ហើយ ឥឡូវគឺសុំសម្រាកបន្តិចទេ សម្រាកនៅទីនេះមួយមីនុតពីរមីនុតទេ ដើម្បីឲ្យខាងសោតទស្សន៍ហ្នឹងគេរៀបចំប្ដូរ ឌីវីឌី ។ សូមមន្ត្រីតុលាការសម្របសម្រួលជាមួយនឹងខាងបច្ចេកទេស ។

[១៥:៤៥:០០]

*(ខាងសោតទស្សន៍កំពុងប្ដូរ ឌីវីឌី សម្រាប់ថតសំឡេង)*

[១៥:៤៧:២៩]

**ប្រធានអង្គជំនុំ៖**

បន្តកិច្ចប្រជុំរបស់យើងបន្តទៀត ពីព្រោះដូចជាបានរីកចម្រើនច្រើនហើយនៅសល់តិចតួចទេ ។ ហើយមេធាវី ហុង គឹមសួន ចង់និយាយខ្លាំងណាស់ ក្រែងលោគាត់ភ័យខ្លាចអត់បាននិយាយ ។ ហើយខ្ញុំបញ្ជាក់ម្ដងទៀត ខ្លាចលោកភ័ន្តច្រឡំ មេធាវីក្រុមបីអំមិញគឺខ្ញុំបានបញ្ជាក់ហើយថា ទីមួយគឺខ្ញុំបានជូនវេទិកាទៅលោកស្រីថៅក្រម ខាតរាយថ៍ ដែលបានបញ្ជាក់អំពីបញ្ហាលទ្ធភាពក្នុងការធ្វើពីចម្ងាយនៅក្នុង

ដែនដីកម្ពុជា គឺច្បាស់លាស់ងាយយល់ថា យើងមិនអាចដំណើរការទៅបានទេ ។ ដោយឡែកពីខាងអន្តរជាតិគឺនិយាយរួមពីនាយសមុទ្ទសូម្បីតែអន្តរជាតិជិតនេះ ត្រឹមតែវៀតណាមកន្លងមកក៏យើងអត់ទាន់ច្បាស់ដែរ ។ ប៉ុន្តែ ខាងពីចម្ងាយយើងបានធ្វើការច្បាស់លាស់ជាមួយខាងភាគី ខាងអ្នកជំនាញ កិច្ចការខាងនេះហើយ ។ ហើយគេបានឆ្លើយតបជាវិជ្ជមានថា គេធ្វើបាន ឯចំណែកពេលវេលាដូចខ្ញុំបាន ជម្រាបម្តងទៀតថា បានគណនាសាកល្បងទៅវាមិនខុសគ្នារហូតដល់យប់ថ្ងៃពេកនោះទេ គ្រាន់តែថា តើយើងធ្វើពេលណាដែលសមស្របជាមួយនឹងឱកាសដែលគេអាចធ្វើនៅឯណោះបាន ហើយយើងធ្វើនៅទីនេះដែលអាចដំណើរការក្នុងម៉ោងយើងបាន អាហ្នឹងយើងនឹងគណនាម្តងទៀត ។ វាអាស្រ័យទៅលើប្រទេសនីមួយៗ ឬតំបន់នីមួយៗដែរ ដែលវាវិលទៅវាអាចខុសម៉ោងគ្នា ជួនកាលខុសកន្លះម៉ោងលម្អៀងនៅក្នុងតំបន់នោះជាមួយនឹងស្រុកយើងទៀត ។ អានេះយើងបានដឹងហើយពីរដ្ឋមួយៗនៃភាគី ដែលត្រូវធ្វើពីចម្ងាយនោះ ។ ហើយអំមិញខ្ញុំបានសួរទៅលោក លោកស្រីចៅក្រម អន្តរជាតិដែលព័ត៌មាននេះលោកលោកស្រី គាត់បានធ្វើការទំនាក់ទំនងផ្ទាល់ខាងអ្នកបច្ចេកទេស ។ ប៉ុន្តែ ដោយសារការបកប្រែភាសាហ្នឹងអត់អស់ តាមខ្ញុំស្តាប់មើលទៅនាំឲ្យគាត់អត់អាចជម្រាបជូននូវ ឬក៏ផ្តល់មតិ យោបល់បញ្ជាក់ថាអ្វីដែលខ្ញុំបាននិយាយអំពីលទ្ធភាពក្នុងការធ្វើពីចម្ងាយនៅឯនាយសមុទ្ទមកទីនេះហ្នឹង ដែលថា យើងបានគិតគូររួចហើយ មិនមានបញ្ហាធំដុំទេ ។ អ៊ីចឹងហើយបានជាយើងយកបញ្ហានេះយកមកដាក់ប្រជុំបាន ។ បើសិនជាយើងដាក់បញ្ហាប្រជុំ ហើយយើងមិនទាន់បានសួរអ្នកជំនាញផង យើងម៉េចនឹងអាចធានាបាននៅក្នុងកិច្ចដំណើរការនេះ ។ អ៊ីចឹងបានន័យថា យើងបានធ្វើការពិគ្រោះយោបល់ អ្នកជំនាញសព្វគ្រប់ហើយ ដែលគេឆ្លើយតបជាវិជ្ជមានហើយទើបយើងធ្វើដាក់របៀបវារៈត្រូវធ្វើនេះ ។

ហើយដោយឡែកបញ្ហាផ្សេងទៀតហ្នឹងគឺយើងបានឆ្លើយតបរួចហើយចំពោះក្នុងស្រុក ។ ហើយប្រហែលជាលោកស្រីចៅក្រម ឬក៏លោកចៅក្រម ហ្សង់ម៉ាក អាចបញ្ជាក់ពីបញ្ហានេះបានអំពីបច្ចេកទេសក្នុងការធ្វើជាមួយនឹងវីដេអូ *ខនហ្វឺរិន* នេះ ឬក៏មានការកែលម្អខ្ញុំបើសិនខ្ញុំនិយាយខុស ។ បើគ្មានបញ្ហាអីទេ សូមអញ្ជើញលោកមេធាវី ហុង គឹមសួន ។

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំបាទសូមគោរពអង្គប្រជុំម្តងទៀត ។ ចំពោះក្រុមទីបួនក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទីបួននេះមិនមានអ្វីចំណោទឬជំទាស់ទេ ។ ប៉ុន្តែ ជាចំណុចមួយដែលខ្ញុំបាទសុំជម្រាបលោកប្រធាន មានកូនក្តីខ្ញុំបាទមួយដែលគាត់នៅបរទេស នៅប្រទេសបារាំង ហើយ

គាត់បានដាក់ជាឯកសារស្នើសុំការថ្លែងសក្ខីកម្ម ឬក៏សុំនិយាយឆ្លងតាមវីដេអូ *ខនហ្វឺរិន* ដូចគ្នា ដែរ។ ប៉ុន្តែ មកដល់ថ្ងៃនេះ ខាងខ្ញុំបាទក៏មិនទាន់បានទទួលថាតើលោកប្រធានបានសម្រេចយ៉ាងម៉េចនោះ ។ អ៊ីចឹងចំណុចរបស់ខ្ញុំបាទមានតែមួយទេ ។ ហើយខ្ញុំបាទក៏បានយល់ដែរ លោកស្រីចៅក្រមគាត់បានជម្រាបអំមិញថា បើក្នុងប្រទេសយើងវាពិបាក ប៉ុន្តែនេះចំពោះជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំប្រទេសដែលជឿនលឿន តើធ្វើបានដែរឬទេ? បើគាត់សុំដូចនេះ? សូមអរគុណ ។

[១៥:៥២:០០]

**ប្រធានអង្គជំនុំ៖**

អរគុណ ។ អ៊ីចឹងខ្ញុំឆ្លើយតបតែម្តងទៅ ព្រោះបញ្ហាហ្នឹងបានជជែកគ្នាច្រើនពីបញ្ហាហ្នឹងហើយ ហើយបញ្ហាដែលយើងលើកមកនេះគឺលើកតែសាក្សី និងអ្នកជំនាញប៉ុណ្ណោះ ។ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើសុំ មានពាក្យសុំថាសុំឲ្យធ្វើតាមរយៈពីចម្ងាយ ឬក៏ប្រើថា វីដេអូ *ខនហ្វឺរិន* នេះ យើងទទួលយល់ព្រមរួចហើយប្រសិនបើយើងធ្វើអានេះបាន យើងធ្វើអានោះបានដោយយើងគិតថា គាត់ចំណាយពេលវេលាខ្លីផងក្នុងការដែលគាត់ចូលរួម ហើយកុំឲ្យគាត់ខ្ជះខ្ជាយពេលវេលា ឬក៏ខាតក្នុងការធ្វើដំណើរទៅមកផង ។ អ៊ីចឹងគឺ ជាវិជ្ជមានបានន័យថាយើងទទួលតាមសំណើ ។ អានេះគឺនិយាយឲ្យច្បាស់ ។ ហើយអ៊ីចឹងបន្តទៀតសូមអញ្ជើញមេធាវី ហ្វ្រង់ស្វ័រ រ៉ូ មេធាវីការពារក្តីមានបញ្ហាអីទេ លើបញ្ហានេះ ។ អំមិញបានកត់សម្គាល់ហើយ តែសូមបញ្ជាក់បន្ថែមទៀត ច្បាស់លាស់ឬនៅៗក្នុងជំហរនៅក្នុងចំណុចរបៀបវារៈទីបួននេះ?

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

សូមអរគុណលោកប្រធាន ។ ជាដំបូងមុននឹងខ្ញុំនិយាយអំពីចំណុចនេះ ទោះបីជាយើងនៅក្នុងការប្រជុំអសាធារណៈក៏ដោយ ខាងមេធាវីការពារក្តីទើបតែទទួលបានដំណឹងថា ការបោះពុម្ពនៅលើវេបសាយរបស់ អ.វ.ត.ក គឺនិយាយថា លោក រ៉ូប៊ឺត ពេទីត គាត់បានលាលែងឈប់ហើយពីថ្ងៃទី១ ខែកញ្ញាទៅ ។ ដូច្នេះខ្ញុំចង់សួរបញ្ជាក់ថាតើ ដូច្នេះមែនឬ? ហើយបើសិនជាដូច្នេះមែន យើងខ្ញុំសូមជូនពរឲ្យគាត់បានជោគជ័យក្នុងអាជីពរបស់គាត់នៅថ្ងៃក្រោយ។ ហើយទាក់ទងនឹងប្រធានបទនាពេលបច្ចុប្បន្ននេះគឺថា មេធាវីការពារក្តីមានការបារម្ភទៅនឹងចំណុចទី ឧបសម្ព័ន្ធទី គ,ឃ នៅពេលដែលខ្ញុំជួបជាមួយនឹងគាត់នោះនៅឯ ឡាហេ គឺ *វីនាត ហ្គូលស្តុន* គាត់បានព្រមព្រៀងក្នុងការផ្តល់សក្ខីកម្មតាមវីដេអូខនហ្វឺរិនស៊ីង ប៉ុន្តែយើងអាចនឹងមានបញ្ហាចំពោះពេលវេលានៃម៉ោងដែលខុសគ្នា ពីព្រោះលោក *ហ្គូលស្តុន*

គឺគាត់រស់នៅសហរដ្ឋអាមេរិក ហើយមានន័យថា ម៉ោងដែលខុសគ្នានោះគឺអាចខុសគ្នាដប់មួយ ឬក៏ដប់ពីរម៉ោងពីម៉ោងនៅស្រុកកម្ពុជា ។ ហើយខ្ញុំចង់ធ្វើការបញ្ជាក់ថា នៅចំពោះមុខតុលាការ អាយស៊ីធីអ សវនាការមួយចំនួនគឺត្រូវបានប្រព្រឹត្តឡើងនៅពេលយប់ ឬមានន័យថាក្រោយពីពិសាអាហារពេលល្ងាចរួច ដើម្បីស្ដាប់សក្ខីកម្មតាមរយៈ *វីដេអូ ខនហ្វឺរិន* ជាមួយនឹងអ្នកដែលនៅខាងក្រៅ ។

[១៥:៥៥:២៣]

ដូច្នេះ ប្រហែលជាយើងស្ថិតនៅក្នុងស្ថានភាពមួយដែលត្រូវរៀបចំផែនការបែបនេះ ។ ខ្ញុំគិតថាប្រហែលជាមិនអាចដាក់កាលកំណត់បែបនេះបានទេ ដើម្បីឲ្យលោក *វីនាត ហ្គូលស្តុន* ហ្នឹងឲ្យគាត់ធ្វើការផ្ដល់សក្ខីកម្មម៉ោងពីរ ឬក៏ម៉ោងដប់ពីរភ្លឺនោះ ។ ហើយខ្ញុំក៏ចង់និយាយទៀតថានៅក្នុងបរិបទ នៃការជួបប្រជុំរបស់ខ្ញុំជាមួយគាត់ ខ្ញុំបានទទួលទូរស័ព្ទទៅលោក *ហេសហ្សេល* ដែលជាឯកអគ្គរាជទូត ដែលថាគាត់នឹងផ្ដល់សក្ខីតាមរយៈ *វីដេអូ ខនហ្វឺរិន* នោះ ។ គឺគាត់ចង់មានវត្តមាននៅក្នុងអង្គសវនាការតែម្ដង ក៏ប៉ុន្តែលោក លោកស្រីដឹងហើយគាត់អាយុ៩២ឆ្នាំហើយ ។

ដូច្នេះ នេះគឺជាការធ្វើការដំណើរមួយដែលលំបាកខ្លាំងណាស់សម្រាប់គាត់ ។ ប៉ុន្តែគាត់បានឯកភាពព្រមព្រាងផ្ដល់សក្ខីកម្មតាមរយៈ *វីដេអូ ខនហ្វឺរិន* ពីទីក្រុងប៉ារីស ។ ហើយទាក់ទងទៅនឹងលោក *ហ្គូលស្តុន* ហើយនិង *ហេសហ្សេល* ខ្ញុំជឿថាយ៉ាងច្រើនបំផុតគឺកន្លះថ្ងៃតែប៉ុណ្ណោះ គឺគ្រប់គ្រាន់ហើយសម្រាប់ការស្ដាប់សក្ខីកម្មរបស់គាត់នីមួយៗ ។ ហើយខ្ញុំយល់ថាប្រហែលជាអាចនឹងស៊ីពេលតិចជាងកន្លះថ្ងៃទៀតផង ។ ក៏ប៉ុន្តែ ទាក់ទងទៅនឹងលោក *ហេសហ្សេល* ឬក៏សាក្សីដទៃទៀតដែលនឹងផ្ដល់សក្ខីកម្មតាមរយៈ *វីដេអូ ខនហ្វឺរិន* នោះ ។ ខ្ញុំចង់ឲ្យលោក លោកស្រីចៅក្រមធ្វើការពិចារណា ដើម្បីឲ្យដឹងថាឲ្យមានសមាជិករបស់ខាងមេធាវីការពារក្ដី ឬក៏សមាជិកម្នាក់ទៀតពីខាងការិយាល័យសហព្រះរាជអាជ្ញា ឲ្យមានវត្តមាននៅក្បែរសាក្សីដែលផ្ដល់សក្ខីកម្មតាម *វីដេអូ ខនហ្វឺរិន* នោះ ។

ហើយខ្ញុំក៏សូមធ្វើការបង្ហាញផងដែរ ទាក់ទងទៅនឹងពេលវេលាដែលបែងចែកកំណត់ឲ្យសាក្សីខាងមេធាវីការពារក្ដី ។ សាក្សីភាគីច្រើនរបស់មេធាវីការពារក្ដី គឺផ្ដល់សក្ខីកម្មខ្លីៗតែប៉ុណ្ណោះ ប្រហែលជាម្ភៃទៅសាមសិបនាទីតែប៉ុណ្ណោះសម្រាប់ពួកគេមួយចំនួន ។

ដូច្នេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះធ្វើការពិចារណាថា នៅក្នុងការចាត់ចែងការស្ដាប់សក្ខីកម្មនោះ និងទាក់ទងនឹងសាក្សីអស់ទាំងហ្នឹង គឺលោក *ហ៊ានរី ឃើង* ដោយសារតែអាយុរបស់គាត់ ក៏បានទទួលឯកភាពផ្ដល់សក្ខីកម្មតាមរយៈ *វីដេអូ ខនហ្វឺរិន* ។ ក៏ប៉ុន្តែ ជាបច្ច័យអាក្រក់គាត់បានស្លាប់ទៅហើយ តែ

គាត់បានផ្តល់នូវសេចក្តីថ្លែងការណ៍អះអាងមួយដែលមានចំនួនមួយសន្លឹក ហើយគាត់បញ្ជាក់អំពីអត្ថន័យនៃសក្ខីកម្មរបស់គាត់ ។ ហើយមេធាវីការពារក្តីសូមស្នើដាក់បញ្ចូលឯកសារនេះនៅក្នុងសំណុំរឿង ។ ហើយសូមឲ្យក្រឡាបញ្ជីធ្វើច្បាប់ចម្លងជាភាសាបារាំង និងជាភាសាអង់គ្លេស ។

ហើយមេធាវីការពារក្តីសូមឲ្យបញ្ចូលឯកសារហ្នឹងនៅក្នុងសំណុំរឿង ព្រមទាំងសៀវភៅរបស់លោក *ហ៊ែនរី ឃីង* ដែលសៀវភៅនោះមានបញ្ចូលនៅក្នុងសំណុំរឿងរួចហើយ ។ ហើយយើងខ្ញុំនឹងប្រើសៀវភៅនោះ ។

[១៥:៥៩:០៨]

ហើយចុងបញ្ចប់លោកប្រធាន មុនពេលដែលយើងដឹងថាការប្រជុំរៀបចំសវនាការត្រូវបានប្តូរមកពេលរសៀលនេះ យើងបានពិភាក្សាជាមួយចៅក្រម ឡាវែន៍ អំពីលទ្ធភាពក្នុងការចូលរួមនៅថ្ងៃព្រហស្បត្តិ៍ ពេលល្ងាចសម្រាប់កម្មវិធីការប្រជុំរៀបចំសវនាការតាមរយៈ *វីដេអូ ខនហ្វឺរិន* ។ តើយើងអាចពន្ធាតនូវគំនិតនេះបានដែរឬទេ? ដើម្បីឲ្យយើងធ្វើការពិភាក្សានៅថ្ងៃព្រហស្បតិ៍ ពីកន្លែងដែលខ្ញុំនៅដើម្បីធ្វើការសាក្សីល្បងទៅលើប្រព័ន្ធ *វីដេអូ ខនហ្វឺរិន* ហ្នឹង ដើម្បីជួយឲ្យខាងអង្គជំនុំជម្រះអាចធ្វើការកំណត់បានទេ? មានន័យថាយើងអាចធ្វើការសាកល្បងប្រព័ន្ធ *វីដេអូ ខនហ្វឺរិន* ហ្នឹងនៅព្រឹកថ្ងៃព្រហស្បតិ៍ពីប្រទេសបារាំង ។ នេះគ្រាន់តែជាសំណើតែប៉ុណ្ណោះលោកចៅក្រម ។

[១៦:០២:១៩]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ហ្វ្រង់ស្វ័រ រូ ដែលបានលើកឡើងបញ្ហានេះ ។ ហើយប្រហែលជាក៏ជាគំនិតខ្ញុំបានឯកភាពដែរពីព្រឹកមិញ ដែលមានបញ្ហាដែលថាលោកមានបញ្ហាគ្រួសារដែលត្រូវត្រឡប់ទៅវិញនោះ ។ ដែលប៉ុនប៉ងថា ពិនិត្យលទ្ធភាពក្នុងជូនឱកាសដល់លោកក្នុងការចូលរួមក្នុងកិច្ចប្រជុំរៀបចំសវនាការនៅរសៀលថ្ងៃព្រហស្បតិ៍ ទី២៥ ខាងមុខ ។ ប៉ុន្តែ នោះជាការរំពឹងផ្នែកខាងអង្គជំនុំជម្រះទេ ប៉ុន្តែតាមព័ត៌មានចុងក្រោយនេះ ខាងបច្ចេកទេសនៅ*អាយធី* នៅទីនេះទាល់តែយើងរៀបចំជាមុន ហើយអាចរយៈពេលយូរ ដោយសារមានការទាក់ទងជាអន្តរជាតិនោះ ។ អ៊ីចឹងគឺកិច្ចដំណើរការដែលថាប៉ុនប៉ងក្នុងការធ្វើសាកល្បងនោះ ប្រហែលជាមិនអាចធ្វើបានទេ ។

អ៊ីចឹងពេលណាដែលយើងធ្វើក្រោយនេះ ក៏យើងត្រៀមលក្ខណៈជាមុន រាប់មានផែនការច្បាស់លាស់ បានយើងអាចដំណើរការបាន ។

[១៦:០៣:៣២]

មានមតិយោបល់អ្វីទៀតទេ? អស់លោក លោកស្រីចៅក្រមមានអ្វីពិភាក្សាទៀតទេ?

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា ។

**លោក វីលៀម ស្មីត៖**

ខ្ញុំសូមនិយាយដោយសង្ខេបនៅថ្ងៃស្អែក គឺថា ដើម្បីឲ្យយើងអាចអនុវត្តការងាររបស់យើងបាន ថាតើយើងចំណាយរយៈពេលប៉ុន្មាន ក្នុងការដេញដោលជនជាប់ចោទទៅលើព្រៃស? ហើយតើភាគីនឹងអនុញ្ញាតឲ្យរយៈពេលប៉ុន្មានដែរក្នុងការផ្តល់ទៅដល់ការដេញដោលសំណួរទៅលើជនជាប់ចោទនោះ?

សូមអរគុណ ។

[១៦:០៦:៥៤]

**ប្រធានអង្គជំនុំ៖**

អរគុណនូវការតាំងសំណួរសួរពាក់ព័ន្ធជាមួយនឹងអំឡុងពេលដែលត្រូវធ្វើការសួរដេញដោលដល់ជនជាប់ចោទ នូវអង្គហេតុដែលយើងគំរោងផែនការនឹងធ្វើ--ការធ្វើសវនាការដេញដោលនៅថ្ងៃស្អែក ។ ចាប់ពីថ្ងៃស្អែកទៅនោះ ហើយតាមការពិគ្រោះពិភាក្សាឯកភាពគ្នា ទីមួយអង្គជំនុំជម្រះប៉ាន់ស្មានថាការធ្វើសវនាការដោយអង្គជំនុំជម្រះនេះ ចំពោះអង្គហេតុការបង្កើតនិងប្រតិបត្តិការស-២៤ ឬហៅថាព្រៃសនោះ ប្រហែលជាយ៉ាងច្រើនមួយថ្ងៃ ។ នេះសម្រាប់អង្គជំនុំជម្រះ ប៉ុន្តែការគិតនេះគឺគិតកម្រិតអតិបរមា ហើយយើងនឹងប្រឹងប្រែងឲ្យមានការកាត់បន្ថយតិចជាងនេះ ។ ហើយដោយឡែកបញ្ហាភាគី អង្គជំនុំជម្រះបានពីភាក្សាគ្នា ហើយឯកភាពសម្រេចដូចនេះ គឺប្រាំមួយម៉ោងសម្រាប់សហព្រះរាជអាជ្ញា ហើយប្រាំមួយម៉ោងសម្រាប់ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុម ។

មួយម៉ោងសម្រាប់សហព្រះរាជអាជ្ញា មួយម៉ោងសម្រាប់ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុម ហើយមួយម៉ោងកន្លះសម្រាប់មេធាវីការពារ ។

**លោក វីលៀម ស្មីត៖**

សូមអរគុណ លោក លោកស្រីចៅក្រម គឺថាខ្ញុំទទួលនូវការជូនដំណឹងពីលោកប្រធានហើយ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណ លោកប្រធាន លោក លោកស្រីចៅក្រម ដូចគ្នានេះដែរ ខ្ញុំសួរអង្គសវនាការ ថាតើអង្គសវនាការនឹងផ្តល់ជាគំនិតដល់យើងអំពីថាតើសាក្សីណាដែលយើងស្តាប់បន្ទាប់ពីស-២៤ នេះ? បាន

ន័យថានៅពេលដែលយើងស្តាប់សក្ខីកម្មលើព្រៃសហើយ តើយើងនឹងស្តាប់សាក្សីមួយណា? ខ្ញុំអភ័យទោសដោយសារតែ ដែលវាពាក់ព័ន្ធទៅនឹងការដែលខ្ញុំត្រូវចាកចេញពីប្រទេសកម្ពុជា ។ ដូច្នេះ ខ្ញុំត្រូវដឹងទៅលើករណីនេះ ដោយសារតែវាមានភាពចាំបាច់ណាស់ចំពោះខ្ញុំ ។

[១៦:១០:១២]

**ប្រធានអង្គជំនុំ៖**

កាលពីថ្ងៃច័ន្ទ ដូចជាអង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីរួចហើយតាមខ្ញុំចាំ គឺបានជម្រាបអំពីការប្រែប្រួល នៃកាលវិភាគសម្រាប់ដំណើរការសវនាការសម្រាប់បីសប្តាហ៍ គិតទាំងសប្តាហ៍នេះ ។ អ៊ីចឹងនៅក្នុងពីរសប្តាហ៍ គឺសប្តាហ៍ក្រោយ ហើយនិងសប្តាហ៍បន្ទាប់នេះ គឺអង្គជំនុំជម្រះនឹងធ្វើសវនាការចំពោះអ្នកដែលរស់រានមានជីវិតនៅមន្ទីរស-២១ ចំនួនប្រាំបួនរូបៗ ។ ហើយ--

មានចំនួនប្រាំបួនរូប ខ្ញុំជម្រាបថា KW-01, D25/3, D25/1, CP1/6, E2/61, E2/23, E2/33/ E2/80, E2/32 សរុបប្រាំបួនរូបនៅក្នុងពីរសប្តាហ៍ទៅមុខនេះ បានន័យថា សប្តាហ៍ក្រោយនិងសប្តាហ៍បន្ទាប់ ។ ដោយសារមានការយឺតយ៉ាវ គឺសូមជម្រាបជូនឲ្យច្បាស់ដើម្បីបន្ថែមទៀតថា ដោយសារយើងត្រូវធ្វើកិច្ចប្រជុំថ្ងៃនេះ ដើម្បីដោះស្រាយបញ្ហាថាតើសាក្សីណាខ្លះ ដែលយើងឯកភាពថាដែលមិនអញ្ជើញគាត់មកធ្វើសវនាការទេ គឺស្តាប់នូវកំណត់ហេតុបាន ដែលយើងបានជជែកអំមិញ ។ អ៊ីចឹងបានជាមានការយឺតយ៉ាវក្នុងផ្តល់ ទោះបីយ៉ាងណាក៏ដោយអង្គជំនុំជម្រះបានឆ្លៀតឱកាសកាលពីថ្ងៃច័ន្ទ បានជម្រាបជូនភាគីរួចហើយ ។ ខ្ញុំគិតថាខ្ញុំនៅចាំច្បាស់ថា ខ្ញុំបានជម្រាបជូនដំណឹងអំពីបញ្ហានេះហើយ ។ ទទួលបានទេលោក ហ្វ្រង់ស្វ័រ រូ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោក លោកស្រីចៅក្រម ដីកាដែលលោកបានបញ្ជាក់ខ្ញុំនេះគឺជាអ្វីដែលលោក លោកស្រីចៅក្រម នឹងអនុវត្តតាមដីកានេះនៅថ្ងៃច័ន្ទ?

**ប្រធានអង្គជំនុំ៖**

គឺ--

**លោក ហ្វ្រង់ស្វ័រ រូ៖**

តម្រូវគឺលំដាប់លំដោយ ។

**ប្រធានអង្គជំនុំ៖**

ពិតណាស់ លំដាប់លំដោយនេះនៃការអញ្ជើញនេះ គឺការប៉ុនប៉ងរបស់អង្គជំនុំជម្រះ គឺធ្វើដូច្នេះៗទៅតាមលទ្ធភាព ។ ដូចខ្ញុំបានជម្រាបអ៊ីចឹង គឺយើងតែងតែអញ្ជើញអ្នកដែលពាក់ព័ន្ធនឹងមកបម្រុងទុកប្រសិនជាមានការខាក់ខាន ឬមានធុរៈណាមួយ គឺយើងយកអ្នកហ្នឹងជំនួស ដើម្បីឱ្យដំណើរការប្រព្រឹត្តទៅកុំឱ្យមានការដាច់ ការអាក់ខានក្នុងការធ្វើសវនាការ ។ នេះជាការគិតរបស់យើងតាំងពីមុនមក ។

[១៦:១៣:៤៣]

អរគុណ ឥឡូវគឺអង្គជំនុំជម្រះ-- អង្គប្រជុំយើងបានដល់ពីបញ្ចប់ហើយ ។ ហើយអស់លោក លោកស្រី អ្នកនាងកញ្ញា ជាសមាជិក សមាជិកា ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំរៀបចំសវនាការទាំងអស់នៅថ្ងៃនេះជាទីរាប់អាន ។ ក្នុងនាមខ្ញុំនិងជំនួសមុខឱ្យចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងទាំងមូលសូមថ្លែងអំណរគុណ ចំពោះវត្តមាន ក៏ដូចជាការចូលរួមយ៉ាងផូសផុលក្នុងការបញ្ចេញនូវមតិយោបល់ចាប់អារម្មណ៍ជាច្រើន ជុំវិញប្រធានដែលយើងបានទើបញ្ចប់ការពិភាក្សាអម្បាញ់មិញនេះ ។

អង្គជំនុំជម្រះសូមធ្វើការវាយតម្លៃខ្ពស់ចំពោះលទ្ធផលបានសម្រេចនូវកិច្ចខំប្រឹងប្រែងរបស់ភាគីទាំងអស់ដែលបានចូលរួមក្នុងកិច្ចប្រជុំ និងបានសហការល្អជាមួយនឹងអង្គជំនុំជម្រះសាលាដំបូង ។

ចំពោះបញ្ហាមួយចំនួននៅសេសសល់ ឬក៏មានទស្សនខុសគ្នាខ្លះ អង្គជំនុំជម្រះនឹងធ្វើការពិចារណាថ្លឹងថ្លែង ដោយយោងផ្អែកទៅលើមតិយោបល់ទស្សននានា ដែលភាគីបានលើកឡើងក្នុងអំឡុងពេលនៃកិច្ចប្រជុំពិភាក្សាកន្លងមកនេះ សំដៅធ្វើយ៉ាងណាឱ្យដំណើរការជំនុំជម្រះរបស់យើងរក្សាបាននូវភាពយុត្តិធម៌ និងប្រកបដោយភាពឆាប់រហ័ស ។

អង្គជំនុំជម្រះសូមថ្លែងអំណរគុណសាជាថ្មីម្តងទៀតដល់សមាជិក និងសមាជិកានៃអង្គប្រជុំ និងអ្នកចូលរួម ដែលបានជ្រោមជ្រែងឱ្យកិច្ចប្រជុំប្រព្រឹត្តទៅបានដោយរលូត ដោយបានខិតខំប្រឹងប្រែងជួយសហការអស់ពីកម្លាំងកាយចិត្ត ។ និងសូមជូនពរអស់លោក លោកស្រី អ្នកនាង កញ្ញា ទទួលបាននឹងជោគជ័យក្នុងការបំពេញមុខងារភារកិច្ច ។ ហើយទន្ទឹមនឹងដែរក៏សូមជូនពរពិសេសដោយឡែកមេធាវីហ្វ្រង់ស្វ័រ រូ សូមធ្វើដំណើរទៅប្រទេសរបស់លោកប្រកបដោយសុវត្ថិភាព ។

អង្គជំនុំជម្រះប្រកាសបិទអង្គប្រជុំ ៕

*[កិច្ចប្រជុំរៀបចំសវនាការបញ្ចប់នៅម៉ោង១៦:១៥នាទី]*